**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នគរបាលយុត្តិធម៌

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ជា ម៉េងគី**
លោក **ខួន ហេងហាក់ស៊ីន**

ណែនាំដោយ
លោក **តា សុទ្ធា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# នគរបាលយុត្តិធម៌

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ជា ម៉េងគី**

លោក **ខួន ហេងហាក់ស៊ីន**

ណែនាំដោយ

លោក **តា សុទ្ធា**



ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទ **ជា ម៉េងគី** និង ខ្ញុំបាទ **ខួន ហេងហាក់ស៊ីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២២-២០២៣។

**សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅដល់**

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំង សាកលវិទ្យាធិការរង គណៈគ្រប់គ្រង រួមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំអស់ពីសមត្ថភាពនូវក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួលក៏ដូចជាបង្ហាត់បង្រៀនក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលនូវធនធានមនុស្សដ៏ល្អប្រពៃដែលជាទំពាំងស្នងឫស្សីជម្រុញឱ្យកម្ពុជាមានការអភិវឌ្ឍន៍ទៅថ្ងៃមុខ។

**ហើយក៏សូមធ្វើការសម្តែងនូវការអរគុណជូនចំពោះ**

លោក **តា សុទ្ធា** ដែលជាគ្រូណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ពួកយើងខ្ញុំដែលបានចំណាយនូវពេលវេលាដ៏មានតម្លៃក្នុងការបណ្តុះបណ្តាលណែនាំ និងតម្រង់ទិសដល់ក្រុមយើងខ្ញុំព្រមទាំងការផ្តល់យោបល់ និងការកែលំអរចំណុចខ្វះខាតក្នុងការសេរសារណា។ ទោះបីជាមានជួបនូវឧបសគ្គជាច្រើនក្នុងការសរសេរក៏ដោយក៏លោកគ្រូតែងតែលើកទឹកចិត្ត និងណែនាំអំពីចំណុចខ្វះខាត ដោយផ្តល់ការពន្យល់យ៉ាងក្បោះក្បាយ និងច្បាស់លាស់ដល់ក្រុមយើងខ្ញុំ។ ពួកខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយដែលមានលោកគ្រូជាសាស្ត្រាចារ្យណែនាំសារណាសម្រាប់ក្រុមយើងខ្ញុំ។

ឆ្លៀតពេលនេះដែរយើងខ្ញុំទាំងពីរសូមប្រសិទ្ធិពរជ័យ សិរីមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ជូនចំពោះលោកអ្នកមានគុណ ថ្នាក់ដឹកនាំ សាស្ត្រាចារ្យណែនាំ លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិទាំងអស់ព្រមទាំងសមាជិកក្រុមដែលបានផ្តល់ជាកម្លាំងកាយចិត្តក្នុងការសម្រេចនូវសារណាបញ្ចប់ការសិក្សានេះ។

# អារម្ភកថា

សារណាមួយនេះគឺជាជំនួយទៅដល់អ្នកដែលមានបំណងចង់សិក្សាអំពីវិស័យនីតិសាស្រ្ត ជាពិសេសនោះ គឺមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីអនុវត្តច្បាប់ និងនិស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រផ្ទាល់តែម្តង។ ស្នាដៃនេះនឹងចូលរួមចំណែកមួយក្នុងការពង្រឹងនីតិរដ្ឋនៅក្នុងប្រទេសជាតិ ក៏ដូចជាលើកស្ទួយវិស័យយុត្តិធម៌ តាមរយៈខ្លឹមសារនៃសារណាដែលបង្ហាញជូនជនរួមជាតិ និងសាធារណៈជន នូវមតិទូទៅ គោលបំណង ឧត្តមគតិ និងការប្តេជ្ញាចិត្តរបស់យើងខ្ញុំ ក្នុងការពុះពារបម្រើជាតិ និងប្រជាជនគ្រប់កាលៈទេសៈ ព្រមទាំងបង្ហាញឱ្យបានច្បាស់អំពីចក្ខុវិស័យពាក់ព័ន្ធនឹងយុត្តិធម៌ដើម្បីបន្តស្តារ និងការពារមាតុភូមិឱ្យបានរុងរឿង នៃយើងឱ្យឈពោះទៅរកអនាគតមួយយ៉ាងត្រចះត្រចង់ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរ ដែលចង់បាននូវភាពយុត្តិធម៌។

គោលបំណងក្នុងការស្រាវជ្រាវរបស់ក្រុមយើង គឺចង់ឱ្យមានការរីកចម្រើននៅក្នុងវិស័យច្បាប់ ទាក់ទងនឹងផ្នែកព្រហ្មទណ្ឌ ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តធម៌ ពីព្រោះនៅក្នុងដំណាក់មួយនេះ គឺពឹងផ្អែកទាំងស្រុងទៅលើសមត្ថភាព និងបច្ចេកទេសឬជំនាញមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបង្កា និងបង្ក្រាបបទល្មើសដែលបានកើតមានឡើងនានា និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារសង្គមកុំឱ្យមានភាពវឹកវរ ដើម្បីចៀសវាងកុំឱ្យមានភាព អសកម្មនៅក្នុងសង្គមជាតិ។

ក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានព្យាយាមធ្វើដោយយកចិត្តទុកដាក់ជាអតិបរមា យ៉ាងណាធ្វើឱ្យសារណានេះទុកជាប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវរបស់ពលរដ្ឋខ្មែរគ្រប់រូប មន្ត្រីនគរបាលដែលទទួល នីតិសម្បទាជានគរបាលយុត្តិធម៌ ឬជាភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការភ្នាក់ងាសាធារណៈដទៃទៀត ដែលមាននីតិសម្បទា ជាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន ពិសេសជាងនេះទៅទៀតសម្រាប់និស្សិត ជំនាន់ក្រោយដែលមានបំណងស្វែងយល់អំពីមន្ត្រីនគរបាលយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ។

ដោយសារណានេះជាស្នាដៃដំបូងរបស់យើងខ្ញុំហេតុនេះ យើងខ្ញុំជឿជាក់ថាអាចមានភាពចន្លោះខ្វះខាត និងមានកំហុស ខ្លះៗជាក់ជាមិនខានឡើយ។ ដូច្នេះយើងខ្ញុំរង់ចាំទទួលរាល់ការរិះគន់ដើម្បីកែលម្អដោយ ក្តីសោមនស្ស ក្នុងន័យស្ថាបនាចំពោះស្នាដៃនេះគ្រប់ពេលវេលា។ យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុតដល់ជនរួមជាតិនៅគ្រប់ទិសទី ដែលបានផ្តល់ជំនឿ និងការគាំទ្រយ៉ាងធំធេងដល់ស្នាដៃនេះ។

# មាតិកា


**សេចក្តីផ្តើម** ....... 1

## ជំពូកទី ១

## សញ្ញាណទូទៅនៃមន្ត្រីនគរបាលយុត្តិធម៌

**ផ្នែកទី១. និដ្ឋភាពទូទៅរបស់មន្ត្រីនគរបាលយុត្តិធម៌** ....... 3

កថាខណ្ឌ១. សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ....... 3

កថាខណ្ឌ២. ការសម្របសម្រួលនិងការត្រួតពិនិត្យលើមន្ត្រីនគរបាលយុត្តិធម៌ ....... 3

កថាខណ្ឌ៣ ការកំណត់សម្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ....... 4

**ផ្នែកទី២ សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌** ....... 4

កថាខណ្ឌ១ មណ្ឌលរដ្ឋបាលបំពេញការងារ ....... 4

កថាខណ្ឌ២. ការពន្លាតសមត្ថកិច្ចដែនដី ....... 5

កថាខណ្ឌ៣. ការមិនគោរពវិធានសមត្ថកិច្ចនិងការបង្គាប់បញ្ជារបស់តុលាការ ....... 5

## ជំពូកទី ២

## នីតិវិធីដើម្បីក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌

**ផ្នែកទី១. ការទទួលបានតាមរយៈការប្រឡងប្រជែង** ....... 5

កថាខណ្ឌ១.លក្ខខណ្ឌដើម្បីប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងមន្ត្រីនគរបាលយុត្តិធម៌ ....... 5

កថាខណ្ឌ២. វិញ្ញាសាប្រឡង ....... 5

កថាខណ្ឌ៣. គណៈមេប្រយោគ ....... 5

**ផ្នែកទី២. ការទទួលបានមន្ត្រីយុត្តិធម៌ក្រៅពីការប្រឡងប្រជែង** ....... 6

កថាខណ្ឌ១. ការទទួលបានតាមរយៈឋានន្តរស័ក្តិ និងមុខងារ ....... 6

កថាខណ្ឌ២ ការទទួលបានដោយស្វ័យប្រវត្តិ ....... 9

**ផ្នែកទី៣. ការតែងតាំង ការធ្វើសម្បថ និងការប្រព្រឹត្តកំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌** ....... 9

កថាខណ្ឌ១. ការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ....... 9

កថាខណ្ឌ២. សម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌ ....... 10

កថាខណ្ឌ៣ កំហុសរបស់មន្ត្រីនគរបាលយុត្តធម៌ក្នុងពេលបំពេញមុខងារ ....... 10

## ជំពូកទី ៣
## បេសកកម្មរបស់នគរបាលយុត្តិធម៌


**ផ្នែកទី១ ដំណាក់កាលនៃការស៊ើបអង្កេត** ........ 13

កថាខណ្ឌ១ សិទ្ធិអំណាចនៅក្នុងការពិនិត្យស្វែងរកបទល្មើស ........ 13

កថាខណ្ឌទី២ ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង ........ 14

កថាខណ្ឌទី៣ ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែង ........ 26

**ផ្នែកទី២ នៅក្នុងដំណាក់កាលស៊ើបសួរស៊ើបសួរ** ........ 29

កថាខណ្ឌទី១ សិទ្ធិអំណាចតាមរយៈដីកា ចាត់ឱ្យស៊ើបសួរជំនួស ........ 29

កថាខណ្ឌ២ កាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលការស៊ើបសួរ ........ 31

កថាខណ្ឌ៣ សមត្ថកិច្ចដែនដី និងកិច្ចដែលត្រូវហាមឃាត់ចំពោះមន្ត្រីនគបាលយុត្តិធម៌ ........ 34

**ផ្នែកទី៣ មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលជំនុំជម្រះ និងនីតិវិធីផ្សេងទៀត** ........ 36

កថាខណ្ឌ១ បេសកកម្មនៅក្នុងដំណាក់កាលនៃសាលាដំបូងរាជធានី-ខេត្ត ........ 36

កថាខណ្ឌ២-បេសកកម្មនៅក្នុងដំណាក់កាលនៃសាលាឧទ្ធរណ៍ ........ 39

កថាខណ្ឌ៣-បេសកកម្មនៅក្នុងដំណាក់កាលនតុលាការកំពូល ........ 41

កថាខណ្ឌ៤ បេសកកម្មរបស់នគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលផ្សេងទៀត ........ 41

**សេចក្តីសន្និដ្ឋាន** ........ 45

**អនុសាសន៍** ........ 46

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

រឿងក្តីព្រហ្មទណ្ឌ គឺជាប្រតិកម្មតាមផ្លូវតុលាការរបស់សង្គមបានន័យថា នៅពេលណាដែលមានការរំលោភច្បាប់ ឬក៏វិធានដែលគ្រប់គ្រងសង្គមពេលនោះ សង្គមនឹងមានប្រតិកម្មតបមួយ។ បើនិយាយឱ្យខ្លី គឺចាប់ពីពេលដែលបទល្មើសមួយ ត្រូវបានប្រព្រឹត្តហូតទៅដល់ការដាក់ទណ្ឌកម្ម នឹងមាននីតិ វិធីមួយត្រូវបាន ដំណើរការហៅថា រឿងក្តីព្រហ្មទណ្ឌ បានន័យថា វាកើតឡើងនៅពេលដែលបទ ល្មើសមួយត្រូវបានប្រព្រឹត្ត រហូតដល់មានការប្រកាសទណ្ឌកម្ម និងអនុវត្តន៍ទណ្ឌកម្ម ឬទោស។ ចំពោះវិធានដែលទាក់ទងដល់ការរៀបចំការប្រព្រឹត្តទៅ និងការវិនិច្ឆ័យនៃរឿងក្តីព្រហ្មទណ្ឌនេះ គឺបង្កើតបានជាសំណុំនៃវិធានមួយហៅថា នីតិវិធីព្រហ្មទណ្ឌនេះឯង ដូច្នេះនីតិវិធីព្រហ្មទណ្ឌ គឺជាសំណុំនៃវិធានដែលគ្រប់គ្រងលើការរៀបចំការប្រព្រឹត្តទៅ និងការវិនិច្ឆ័យនៃរឿងក្តីព្រហ្មទណ្ឌ ដើម្បីធានានូវប្រសិទ្ធភាព នៃដំណើរការរបស់តុលាការ ក៏ដូចជាស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។ ម្យ៉ាងទៀត នីតិវិធីព្រហ្មទណ្ឌនេះ ត្រូវបានរៀបចំឡើងនៅក្នុងគោលដៅសំខាន់ៗ ជាអាទិ៍ ដូចជាទាក់ទងទៅដល់ការកំណត់សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់យុត្តាធិការព្រហ្មទណ្ឌជាពិសេសយើងហៅថាតុលាការព្រហ្មទណ្ឌ។ និងទាក់ទៅដល់បែបបទនីតិវិធីនៃការពិនិត្យការចោទប្រកាន់បទល្មើស ការស្រាវជ្រាវរកជនល្មើស ការស្វែងរកភស្តុតាង ព្រមទាំងនីតិវិធីនៃការជំនុំជម្រះជនល្មើស។ ហើយក៏ទាក់ទងផងដែរ ទៅនឹងករណីនៃការរៀបចំផ្លូវនៃបណ្តឹងតវ៉ា ចំពោះការសម្រេចរបស់តុលាការព្រហ្មទណ្ឌ ក៏ដូចជាបែបបទនៃការអនុវត្តទោសព្រហ្មទណ្ឌ ដែលតុលាការព្រហ្មទណ្ឌបានកំណត់ច្បាស់។ ដូច្នេះបើយើងនិយាយដោយសង្ខេប គោលបំណងធំបំផុត របស់នីតិវិធីព្រហ្មទណ្ឌគឺធានានូវប្រសិទ្ធភាពនៃការបង្ក្រាបផង ហើយក៏ធានានូវសិទ្ធិ និង សេរីភាពរបស់បុគ្គលដែលពាក់ព័ន្ធផងដែរ ចំណុចមួយទៀត បើសិនជាយើងពិនិត្យ មើលទៅលើដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ គឺអាចចែកចេញជា ៤ (បួន) ដំណាក់ កាល ទៅតាមលំដាប់លំដោយដូចតទៅ ៖

**ក ៖ ការស៊ើបអង្កេត** ដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា ។

**ខ ៖ ការចោទប្រកាន់** ដែលធ្វើឡើងដោយព្រះរាជអាជ្ញាស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**គ ៖ ការស៊ើបសួរ** ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ឬយុត្តាធិការ ស៊ើបសួរ ។

**ឃ៖ ការជំនុំជម្រះ** ដែលធ្វើឡើងដោយចៅក្រមជំនុំជម្រះ ឬយុត្តាធិការជំនុំជម្រះ។ បើតាមការរៀបរាប់ខាងលើឃើញថា រឿងក្តីព្រហ្មទណ្ឌ គឺមានពាក់ព័ន្ធដល់ស្ថាប័នជាច្រើន ដែលក្នុងនោះរួមមាន ៖ ស្ថាប័ននគរបាលយុត្តិធម៌, ស្ថាប័នអយ្យការ, ស្ថាប័នស៊ើបសួរ និងស្ថាប័នជំនុំជម្រះជាដើម។ ដោយហេតុថាការសរសេរសារណារបស់យើងខ្ញុំបាទ លើកយកមកសិក្សាតែទៅលើ **នគរបាលយុត្តិធម៌** ប៉ុណ្ណោះអាស្រ័យ ហេតុនេះយើងខ្ញុំបាទនឹងព្យាយាមពន្យល់ឱ្យបានលម្អិតនូវ ៖

- ជំពូកទី ១ **សញ្ញាណទូទៅរបស់នគរបាលយុត្តិធម៌**
- ជំពូកទី ២ **នីតិវិធីដើម្បីក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌**
- ជំពូកទី ៣ **បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌**

ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១
# សញ្ញាណទូទៅនៃមន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី ១
# សញ្ញាណទូទៅនៃមន្ត្រីនគរបាលយុត្តិធម៌

## ផ្នែកទី១. និដ្ឋភាពទូទៅរបស់មន្ត្រីនគរបាលយុត្តិធម៌

### កថាខណ្ឌ១. សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ មានន័យថានគរបាលយុត្តិធម៌ជា ជំនួយរបស់អំណាចព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរក្នុងការត្រួតពិនិត្យបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិម និងបទល្មើសលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង[1]។

ព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តដីកាចាត់ចែងឲ្យស៊ើបសួរ ជំនួសមន្ត្រីនគបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ (មាត្រា៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌដាក់នគរបាលយុត្តិធម៌ស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ (មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)[2] ។

សមាសភាពរបស់នគរបាលយុត្តិធម៌រួមមាន៖

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលយុត្តិធម៌

-មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន[3]។

### កថាខណ្ឌ២. ការសម្របសម្រួលនិងការត្រួតពិនិត្យលើមន្ត្រីនគរបាលយុត្តិធម៌

#### ២.១ ការសម្របសម្រួលសកម្មភាពការងាររបស់នគរបាលយុត្តិធម៌

ព្រះរាជអាជ្ញាដឹកនាំនិងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។

---

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៦។

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៩។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៧។

ព្រះរាជអាជ្ញាមានអំណាចទៅលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលចែងនៅក្នុងមាត្រា ៨២ (ការផ្ដល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត)នៃក្រមនេះ កាលណាមន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌។

កាលណាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ[4]។

**២.២ ការត្រួតពិនិត្យលើមន្ត្រីនគរបាលយុត្តិធម៌**

នគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌[5]។

**កថាខណ្ឌ៣ ការកំណត់សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌**

**៣.១សមត្ថកិច្ចសម្ភារៈ**

តាមក្រមនីតិវិធីព្រហ្មទណ្ឌ កងរាជអាវុធហត្ថក៏ជានគរបាលយុត្តិធម៌ដែរ។ ហេតុនេះ កងរាជ អាវុធហត្ថអាចបំពេញមុខងារជានគរបាលយុត្តិធម៌នៅក្នុងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ។ ប៉ុន្តែចំពោះបទ ល្មើសយោធាមានតែកងរាជអាវុធហត្ថដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌[6]។ ក្រៅពីនេះ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើមិន អាចស៊ើបអង្កេតបទល្មើសផ្សេងទៀត។

**៣.២ អំណាចរបស់នគរបាលយុត្តិធម៌**

ក្រមនីតិវិធីព្រហ្មទណ្ឌអុំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅតាមក្រមខ័ណ្ឌនៃការស៊ើបអង្កេតថាការស៊ើបអង្កេតករណីជាក់ស្ដែង ឬការស៊ើបអង្កេតបឋម។

## ផ្នែកទី២ សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

### កថាខណ្ឌ១ មណ្ឌលរដ្ឋបាលបំពេញការងារ

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅបំពេការងារ។

នៅភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃក្រុងទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះ នៅកន្លែងណាក៏ដោយ ។

សេចក្ដីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែបញ្ជាក់មណ្ឌលរដ្ឋបាលដែលមន្ត្រីនោះចាត់តាំងឱ្យទៅបំពេការ។ សេចក្ដីសម្រេចនេះ ត្រូវផ្ដល់ដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[7]។

---

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៨។

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៩។

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨១។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៧។

**កថាខណ្ឌ២. ការពន្លាតសមត្ថកិច្ចដែនដី**

ក្នុងករណីបទឧក្រិដ្ឋ ឬបទបដ្ឋិមជាក់ស្តែងតាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទបដ្ឋិមជាក់ស្តែង) និងមាត្រា៨៧ (ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ហើយប្រសិនបើមានការបន្ទាន់ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល។ ការអនុញ្ញាតអាចធ្វើដោយផ្ទាល់បាត់ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត។

ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួសក្នុងករណីបន្ទាន់ចៅក្រមនេះ អាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីជាតិទាំងមូល។

កាលណាធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងផែនដី។ ចៅក្រមដែលបានអនុញ្ញាតឱ្យមានការពន្លាតសមត្ថកិច្ចត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងផែនដី[៨]។

**កថាខណ្ឌ៣. ការមិនគោរពវិធានសមត្ថកិច្ចនិងការបង្គាប់បញ្ជារបស់តុលាការ**

**៣.១. ផលវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច**

វិធាននៃសមត្ថកិច្ចខាងផែនដី ដែលបានបញ្ញត្តិនៅក្នុងមាត្រាមុនៗនេះមានលក្ខណៈដាច់ខាត។ បើមិនគោរពតាមនោះ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ[៩]។

**៣.២. សេចក្តីបង្គាប់បញ្ជារបស់អាជ្ញាធរតុលាការ**

មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញបេសកកម្មរបស់ខ្លួនទទួលបញ្ជា ឬសុំបញ្ជាតែពីអាជ្ញាធរតុលាការ[10]។

---

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៨។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៦៩។

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៧០។

# ជំពូកទី ២
# នីតិវិធីដើម្បីក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី ២
# នីតិវិធីដើម្បីក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌

## ផ្នែកទី១. ការទទួលបានតាមរយៈការប្រឡងប្រជែង

### កថាខណ្ឌ១.លក្ខខណ្ឌដើម្បីប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងមន្ត្រីនគរបាលយុត្តិធម៌

យោងតាមមាត្រា ៦០នៃនីតិវិធីព្រហ្មទណ្ឌ អ្នកប្រឡងប្រជែងទាល់តែជា[11]៖

**១.១ មន្ត្រីនគរបាលជាតិ**

មន្ត្រីនគរបាលជាតិ គឺសំដៅលើមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដែលមានឋានន្តរសក្តិ ចាប់ពីអនុសេនីយ៍ត្រី (សក្តិ១) ឡើងទៅ ហើយគាត់បានបម្រើការងារយ៉ាងតិចបំផុតរយៈពេល ២ឆ្នាំ នៅក្នុងនគរបាលជាតិ និងថែមទាំងបានប្រឡងជាប់សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ទៀតផង ដូច្នេះគាត់នឹងក្លាយខ្លួនទៅជាមន្ត្រីនគរបាលយុត្តិធម៌។

**១.២ នាយទាហាននៃកងរាជាហាវុធហត្ថ**

នាយទាហាននៃកងរាជាហាវុធហត្ថ គឺសំដៅទៅលើនាយទាហាននៃកងរាជអាវុធហត្ថ នៃក្រសួងការពារជាតិដែលមាន (សក្តិ១) ឡើងទៅ និងបានបម្រើការងារយ៉ាងតិចបំផុតរយៈពេល ២ឆ្នាំ នៅក្នុងមុខងារនៃកងរាជអាវុធហត្ថរបស់គាត់ ហើយបានប្រឡងជាប់សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ផងដែរ ពេលនោះគាត់នឹងក្លាយខ្លួនទៅជា មន្ត្រីនគរបាលយុត្តិធម៌ដូចគ្នានឹងមន្ត្រីនគរបាលខាងលើ។

### កថាខណ្ឌ២. វិញ្ញាសាប្រឡង

វិញ្ញាសាប្រឡង គឺត្រូវឆ្លងកាត់ការប្រឡងបែបវិជ្ជាជីវៈនូវវិញ្ញាសាជាមូលដ្ឋានចំនួន ៣មានដូចជា ៖

**ក** ៖ នីតិព្រហ្មទណ្ឌទូទៅ ដែលរយៈពេលប្រឡងគឺកំណត់ដោយគណៈមេប្រយោគ

**ខ** ៖ នីតិវិធីព្រហ្មទណ្ឌ ដែលរយៈពេលប្រឡងគឺកំណត់ដោយគណៈមេប្រយោគ

**គ** ៖ករណីយកិច្ចសាស្ត្រ ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលតាក់តែងឡើងដោយអង្គការសហប្រជាជាតិ ដែលពេលប្រឡងក៏ដូចខាងលើដែរ ។[12]

### កថាខណ្ឌ៣. គណៈមេប្រយោគ

សម្រាប់សមាសភាពគណៈមេប្រយោគនៃការប្រឡងប្រជែង ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដែលទទួលនូវមុខងារនេះកំពូលហើយសមាសភាពគណៈមេប្រយោគដែលទាក់ទងនឹងមន្ត្រីនគរបាលជាតិ ឬយោធិននៃកងរាជអាវុធហត្ថមានដូចតទៅ ៖

---

[11] កៅ សីហា, នគរបាលយុត្តិធម៌ (ភ្នំពេញ, ២០១០), ៨។

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦១។

- ចៅក្រមស៊ើបសួរ ១រូប ដែលតែងតាំងដោយប្រធានតុលាការកំពូល
- ចៅក្រមអយ្យការ ១រូប ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- តំណាង ២(ពីរ)រូប មកពីក្រសួងមហាផ្ទៃ ឬមួយក៏មកពីក្រសួងការពារជាតិទាំងនេះ គឺអាស្រ័យទៅតាមការប្រឡងរបស់ខាងមន្ត្រីនគរបាលជាតិ ឬក៏ខាងយោធិននៃកងរាជអាវុធហត្ថ ។

**ចំណាំ** ៖ នៅពេលដែលគាត់ប្រឡងជាប់ទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌រួចហើយ សញ្ញាប័ត្រនេះ[13] នឹងត្រូវបានចុះហត្ថលេខា និងមានបោះត្រារួមផងដែរ ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ មានន័យថា បើជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចេញមកពីខាងនគរបាលជាតិ គឺចុះហត្ថលេខា និងបោះត្រាដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តែបើសិនជាមកពីខាងកងរាជអាវុធហត្ថ គឺហត្ថលេខា និងបោះត្រា ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីក្រសួងកាពារជាតិ[14]។

## ផ្នែកទី២. ការទទួលបានមន្ត្រីយុត្តិធម៌ក្រៅពីការប្រឡងប្រជែង

### កថាខណ្ឌ១. ការទទួលបានតាមរយៈឋានន្តរស័ក្តិ និងមុខងារ

ចំពោះឋានន្តរស័ក្តិ និងមុខងារនេះ ត្រូវបានផ្តល់ឱ្យដោយការតែងតាំងពីសំណាក់ព្រះមហាក្សត្រ គឺព្រះរាជក្រឹត្យ ឬប្រមុខរាជរដ្ឋាភិបាល គឺអនុក្រឹត្យ ឬក៏ប្រកាសរបស់ប្រធានក្រសួងស្ថាប័ន។ ប៉ុន្តែដោយយល់ឃើញថាមាត្រា ៦០ វាក្យខណ្ឌទី ៣ នៃកថាខណ្ឌទី ១ ក្នុងក្រមនេះ បានចែងនូវចំណុចជាច្រើន ដែលពាក់ព័ន្ធទៅដល់ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌តាមរយៈឋានន្តរស័ក្តិ និងមុខងារ ដូច្នេះហើយដើម្បីងាយស្រួលយល់ យើងសូមធ្វើការបែងចែកជា ៦ ចំណុចផ្សេងៗគ្នា ដូចខាងក្រោម ៖

#### ១.១ អភិបាល និងអភិបាលរង

នៅក្នុងចំណុច **ក** នៃមាត្រាខាងលើមានដូចជា អភិបាល និងអភិបាលរងរាជធានី-ខណ្ឌ អភិបាល និងអភិបាលរងក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ដែលមុខងាររបស់ពួកគាត់ គឺកើតឡើងពីការតែងតាំង (មាត្រា១៤១) នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី-ខេត្ត-ក្រុង-ស្រុក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨)។

#### ១.២ មេឃុំ និងចៅសង្កាត់

នៅក្នុងចំណុច **ក** នៃមាត្រាដដែល ក៏មានចែងផងដែរពីមេឃុំ និងចៅសង្កាត់ ដែលមុខងាររបស់ពួកគាត់ គឺកើតឡើងពីការបោះឆ្នោតជាសកល ។

[13] សញ្ញាប័ត្រនេះមានគំរូបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៧។

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦២។

**១.៣ ប្រធាន និងអនុប្រធាននាយកដ្ឋាន ការិយាល័យផ្នែកប៉ុស្តិ៍ និងអង្គភាពផ្សេងទៀត**

នៅក្នុងចំណុច **ខ គ ឃ ច ជ ឌ ឆ ឈ ញ** នៃមាត្រានេះសំដៅលើ ៖

ចំណុច "**ខ**" គឺប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាល សណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។

ចំណុច "**គ**" គឺប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

ចំណុច "**ឃ**" គឺប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃ ៖

-នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"

-នាយកដ្ឋាននគរបាលទេសចរណ៍

-មន្ទីរប្រឆាំងគ្រឿងញៀន

-ស្នងការពិសេសការពារបេតិកភណ្ឌ។

ចំណុច "**ច**" គឺប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌ ចំណុះស្នងការនគរបាលរាជធានីខេត្ត ដូចជា ៖

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ និង កម្រិតស្រាល

-ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

-ការិយាល័យនគរបាលសេដ្ឋកិច្ច

-ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-ការិយាល័យប្រឆាំងគ្រឿងញៀន

–ការិយាល័យប្រឆាំងភេរវកម្ម

-ការិយាល័យជនបរទេស ។

ចំណុច **ឆ** គឺប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ។

ចំណុច **ជ** គឺប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ, ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ" ប្រធាន និង អនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធជាតិផ្ទុះ" ។ ប្រធាន និង អនុប្រធាន

អង្គភាពប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍ ។

ចំណុច **ឈ** គឺប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ" ។

ចំណុច **ឌ** គឺ ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ចំណុច **ឍ** គឺប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើង ក្នុងករណីចាំបាច់ ។

**១.៤ ស្នងការ និងស្នងការរងនគរបាល**

ចំណុច "**ង**" នៃមាត្រានេះ សំដៅលើស្នងការ និងស្នងការរងនគរបាលរាជធានី-ខេត្ត ។

**១.៥ អធិការ និងអធិការរងនគរបាល**

ចំណុច "**ឆ**" នៃមាត្រានេះដែរ សំដៅលើអធិការ និងអធិការរងនគរបាលក្រុង-ស្រុក-ខណ្ឌ ។

**១.៦ មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ**

នៅក្នុងចំណុច "**ញ ដ ឋ**" នៃមាត្រានេះមាន ៖

ចំណុច **ញ** គឺសំដៅលើមេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថ ទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌប្រចាំក្រសួងការពារជាតិ ។

ចំណុច **ដ** គឺសំដៅលើមេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌប្រចាំរាជធានី-ខេត្ត ។

ចំណុច "**ឋ**" គឺសំដៅលើមេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថ ទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌប្រចាំក្រុង-ស្រុក-ខណ្ឌ[15]។

ដូច្នេះអ្នកដែលមានឋានន្តរស័ក្តិ និងមុខងារ ដូចដែលបានរៀបរាប់ពីខាងលើនេះ ត្រូវទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ដែលពួកគាត់ទាំងនេះ គឺជាជំនួយយ៉ាងសំខាន់ឱ្យស្ថាប័នតុលាការ ។

[15] ដោយសារតែមានការកែប្រែការគ្រប់គ្រងរដ្ឋបាលដែនដីទើបយើងធ្វើការកែប្រែពាក្យពេចន៍ឲ្យស្របទៅតាមបរិបទថ្មីនៃរដ្ឋធម្មនុញ្ញដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ហើយត្រូវបានធ្វើវិសោធនកម្មថ្មីត្រង់មាត្រា ១៤៥ ហ្នឹង ១៤៦ ថ្មី (មួយ) នឹងស្របទៅតាមបរិបទថ្មីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ (មាននៅក្នុងឧបសម្ព័ន្ធទី១)

**កថាខណ្ឌ២ ការទទួលបានដោយស្វ័យប្រវត្តិ**

តើមានអត្ថន័យយ៉ាងដូចម្តេច ចំពោះការទទួលបានដោយស្វ័យប្រវត្តិនូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌នោះ? មានន័យថា ជនទាំងឡាយណាដែលបានបំពេញ នូវលក្ខខណ្ឌមុនក្រមនេះចូលជាធរមាននោះនឹងមានការផ្តល់ជូនដល់គាត់នូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ដូច្នេះយើងនឹងលើកយកមកសិក្សាគួរនូវបុគ្គល ២ ប្រភេទ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម[16] ៖

**២.១.ចំពោះនាយនគរបាលជាតិ**

សំដៅទៅរកនាយនគរបាលជាតិ ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សា ស្តីពី "មន្ត្រីនគរបាលយុត្តិធម៌" ដែលចេញឱ្យដោយសាលាភូមិន្ទនគរបាលនៅមុនពេលក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះចូលជាធរមានត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌[17]។

**-សេចក្តីបញ្ជាក់** ៖ នាពេលបច្ចុប្បន្ននេះ សាលាភូមិន្ទនគរបាល ត្រូវបានប្តូរឈ្មោះទៅជាសាលាបណ្ឌិត្យសភានគរបាល វិញហើយ ។

**២.២.ចំពោះនាយទាហាននៃកងរាជអាវុធហត្ថ**

សំដៅទៅរកនាយទាហាននៃកងរាជអាវុធហត្ថ ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្តីពី "មន្ត្រីនគរបាលតុលាការ" មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ។

## ផ្នែកទី៣. ការតែងតាំង ការធ្វើសម្បថ និងការប្រព្រឹត្តកំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌

### កថាខណ្ឌ១. ការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌

បន្ទាប់ពីទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌រួចហើយ ពួកគាត់ត្រូវទទួលបាននូវការតែងតាំងជាមុនសិន ។ អាស្រ័យហេតុនេះទើបមានសំណួរពីរបានចោទឡើងថា ៖តើបុគ្គលមានឋានៈប៉ុនណាដែលមានសិទ្ធិអំណាចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌? តើមានសេចក្តីសម្រេចប្រភេទណាដែរក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌នោះ? ដើម្បីឆ្លើយនឹងសំណួរនេះបានយើងខ្ញុំធ្វើការបកស្រាយនៅខាងក្រោម ៖

**១.១ បុគ្គលដែលមានសិទ្ធិអំណាចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌**

បុគ្គលដែលមានសិទ្ធិអំណាចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ គឺជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីក្រសួងសាមីនៃបេក្ខជន ព្រោះបើផ្អែកតាមមាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ត្រង់កថាខណ្ឌចុងក្រោយបង្អស់ បានចែងថា "រដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាល ឬជាអាណាព្យាបាល នៃ

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦០៧។

[17] វិញ្ញាបនបត្រនេះមានគំរូបង្ហាញនៅក្នុងឧបសម្ព័នទី៧។

នាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំនុចទី១ ទី២ ទី៣ នៃមាត្រានេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហាននៃកងរាជអាវុធហត្ថទាំងឡាយណា ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌" ។

### ១.២ សេចក្តីសម្រេចក្នុងការតែងតាំងជាមន្ត្រីនគបាលយុត្តិធម៌

សេចក្តីសម្រេចក្នុងការតែងតាំងជាមន្ត្រីនគបាលយុត្តិធម៌ គឺប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមួយរដ្ឋមន្ត្រីក្រសួងសាមីបេក្ខជន មានន័យថា បើពួកគាត់ជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចេញមកពីខាងនគរបាលជាតិ គឺត្រូវបានតែងតាំងដោយប្រកាសរួម" រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តែបើសិនជាពួកគាត់មកពីខាងកងរាជអាវុធហត្ថ គឺត្រូវបានតែងតាំងដោយ "ប្រកាសរួម" រវាងរដ្ឋមន្ត្រីក្រសួងការពារជាតិជាមួយរដ្ឋបន្ត្រីក្រសួងយុត្តិធម៌[18] ។

## កថាខណ្ឌ២. សម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលរដ្ឋមន្ត្រីក្រសួងសាមីជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចេញប្រកាសរួមតែងតាំងគាត់រួចមន្ត្រីនគរបាលយុត្តិធម៌ មិនអាចទៅបំពេញមុខងារនេះបានភ្លាមនោះទេ គឺគាត់ត្រូវឆ្លងកាត់ដំណាក់កាលមួយផ្សេងទៀត ដែលច្បាប់ឱ្យឈ្មោះថា "ការធ្វើសម្បថ"។ យើងនឹងលើកយកមកបង្ហាញនូវ ២ ចំណុចទាក់ទងនឹងបញ្ហានេះ ៖

### ២.១ ទីកន្លែងដែលត្រូវធ្វើសម្បរបស់មន្ត្រីនគរបាលយុត្តិធម៌

យោងតាមមាត្រា ៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវទៅធ្វើសម្បថនៅមុខសាលាឧទ្ធរណ៍ ។ រីឯរូបមន្តនៃសម្បថវិញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[19] ។

### ២.២ អញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីនគបាលយុត្តិធម៌

យោងតាមមាត្រាខាងលើ មានករណីលើកលែងមួយចំពោះសម្បថ ព្រោះបានកំណត់ថា "សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត" ។

## កថាខណ្ឌ៣ កំហុសរបស់មន្ត្រីនគរបាលយុត្តធម៌ក្នុងពេលបំពេញមុខងារ

ក្រោយពេលដែលទទួលបានការតែងតាំងពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ និងក្រោយពីបានធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍រួចមក មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិអំណាចស្របច្បាប់នៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ដូចដែលបានផ្តល់ឱ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌ។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ប្រព្រឹត្តកំហុសក្នុងពេលអនុវត្តមុខងាររបស់ខ្លួន តើនឹងមានទណ្ឌកម្មយ៉ាងដូចម្តេចចំពោះមន្ត្រីនគរបាល

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦០ និងមាត្រា ៦០៧។

[19] សម្បថនេះត្រូវសម្បថថា "ខ្លួននឹងបំពេញដោយទាក់ដីភាពនៅមុខងាររបស់ខ្លួន" មានគំរូនៅក្នុងឧបសម្ព័ន្ធទី៦។

យុត្តិធម៌? ហើយដើម្បីដាក់ទណ្ឌកម្មបាន តើច្បាប់ត្រូវមាននីតិវិធីខាងវិន័យបែបណាខ្លះ? យើងខ្ញុំនិងធ្វើការបកស្រាយនៅខាងក្រោមនេះ ៖

**៣.១ នីតិវិធីខាងវិន័យ**

រាល់កំហុសទាំងឡាយ ដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងពេលអនុវត្តមុខងាររបស់ខ្លួន ត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីផ្តើមដំណើរការនីតិវិធីវិន័យ។ អគ្គព្រះរាជអាជ្ញអមសាលាឧទ្ធរណ៍ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការជាបន្តនៃនីតិ វិធីវិន័យនេះ[20] ។

**៣.២ ទណ្ឌកម្មចំពោះមន្ត្រីនគរបាលយុត្តិធម៌**

ចំពោះទណ្ឌកម្មទាំងអស់នេះ យើងសូមធ្វើការបែកចែកជា ទណ្ឌកម្មខាងវិន័យ (ចំនុចទី១) និងការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ (ចំនុចទី២) ។

**៣.២.១ ទណ្ឌកម្មខាងវិន័យ**

ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬមួយរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។ កាលណាមន្ត្រីនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន យុត្តាធិការស៊ើបសួរ ឬក៏ជំនុំជម្រះដែលទទួលបន្ទុករឿងក្តីមួយនេះ ត្រូវផ្ទេរសំណុំរឿងតាមសេចក្តីសម្រេចរបស់តុលាការកំពូលទៅឱ្យយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា[21] ។

**៣.២.២ ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌**

នៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា សភាពធ្ងន់ធ្ងរនៃកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មានវិសមិតភាពជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោម ៖

-ទីមួយ ៖ ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បណ្តោះអាសន្ន សម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើនបំផុត ។

---

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៤។

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៥។

-ទីពីរ ៖ ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរមុននឹងចេញសេចក្តីសម្រេចហាមរបស់ខ្លួន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍កោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាសេចក្តីសង្កេតរបស់មន្ត្រីនោះទុក។ ចំណែកសាមីជនអាចរកជំនួយពីមេធាវី ឬពីទីប្រឹក្សាម្នាក់ តាមការជ្រើសរើសរបស់ខ្លួន ។ ចំពោះសេចក្តីសម្រេចពីការហាមឃាត់ ត្រូវតែបញ្ជាក់សំអាងហេតុ និងត្រូវផ្តល់ជាដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិទៅតាមករណីនីមួយៗ។ សេចក្តីសម្រេចនេះ អាចជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅរដ្ឋមន្ត្រីកសួងយុត្តិធម៌ដែលអាចប្រកាសបដិសេធចោលការសម្រេចហាមឃាត់ បន្ថយរយៈពេលនៃការហាមឃាត់របស់អគ្គព្រះរាជអាជ្ញា។ ក្រសួងសាមីនៃមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ អាចបញ្ជូនយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បាន។ មន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់ អាចដាក់ពាក្យប្តឹងតវ៉ាដោយមានសំអាងហេតុបានតែក្នុងអំឡុងពេល ១៥ ថ្ងៃប៉ុណ្ណោះគិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចហាមឃាត់នោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ាខាងលើក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ខែ គិតពីថ្ងៃទទួលពាក្យប្តឹង។ សេចក្តីសម្រេចនេះមិនអាចប្តឹងតវ៉ាបានឡើយ។ ក្នុងអំឡុងពេលដែលអាចធ្វើបណ្តឹងតវ៉ានិងអំឡុងពេលនៃការសម្រេចសេចក្តីលើបណ្តឹងតវ៉ាមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ឡើយ មន្ត្រីនេះអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ វិញបានប្រសិនបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់នោះ។ កិច្ចទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌ បានបំពេញដោយបំពានលើសេចក្តីសម្រេចស្តីពីការហាមឃាត់ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នេះ ត្រូវចាប់ទុកជាមោឃៈ[22]។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៦។

# ជំពូកទី ៣
# បេសកម្មរបស់នគរបាលយុត្តិធម៌

# ជំពូកទី ៣
# បេសកកម្មរបស់នគរបាលយុត្តិធម៌

តើនគរបាលយុត្តិធម៌មានបេសកកម្មយ៉ាងដូចម្ដេចខ្លះ នៅក្នុងដំណើរការនៃរឿងក្ដីព្រហ្មទណ្ឌ? យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌនគរបាលយុត្តិធម៌ គឺជាជំនួយរបស់តុលាការនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ។ ហើយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានដូចជានីតិវិធីនៃការស៊ើបអង្កេត នីតិវិធីនៃការស៊ើបសួរ នីតិវិធីការជំនុំជម្រះ និងនីតិវិធីមួយចំនួនផ្សេងទៀត ដូចជានីតិវិធីប្រតិបត្តិ និងនីតិវិធីដោយឡែក។ បើយើងពិនិត្យឱ្យបានលម្អិតចាប់ពីមាត្រា១ រហូតដល់មាត្រា៦១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឃើញថានគរបាលយុត្តិធម៌ត្រូវបំពេញបេសកកម្មមួយចំនួនធំ ដូចបានកំណត់នៅក្នុងមាត្រាមួយចំនួនផ្សេងៗពីគ្នាដើម្បីជួយសម្រួលដល់ស្ថាប័ន តុលាការក្នុងការស្វែងរកយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋខ្លួន។ ដោយយោងតាមអត្ថន័យនេះហើយទើបនៅក្នុងជំពូកទី៣ នេះយើងខ្ញុំបាទសូមធ្វើការបែកចែកនូវបេសកកម្មនគរបាលយុត្តិធម៌ជា ៣ផ្នែក ដើម្បីធ្វើការបកស្រាយអោយបានលម្អិត ៖

## ផ្នែកទី១ ដំណាក់កាលនៃការស៊ើបអង្កេត

មន្ត្រីនគរបាលយុត្តិធម៌ជាជំនួញរបស់តុលាការ រាល់ការស៊ើបអង្កេតដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវជាការសម្ងាត់ (គោលការសំងាត់នៃការស៊ើបអង្កេត)។ បុគ្គលទាំងឡាយដែល ចូលរួមក្នុងការស៊ើបអង្កេតជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចក្នុងការត្រួត ពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រត្រូវរក្សាការសម្ងាត់ខាងវិជ្ជាជីវៈ។ ហើយការបំពាននូវការ សម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើស ដែលត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន[23]។

### កថាខណ្ឌ១ សិទ្ធិអំណាចនៅក្នុងការពិនិត្យស្វែងរកបទល្មើស

ចំណុចទីមួយនេះ មានបែងចែកជាចំណុចសំខាន់តូចៗទៀតដូចជា ការពិនិត្យស្វែងរកបទល្មើសដោយខ្លួនឯង (ចំណុច ១.១) និងការពិនិត្យស្វែងរកបទល្មើសតាម រយៈពាក្យបណ្ដឹង (ចំណុច ១.២) ។

#### ១.១ ការពិនិត្យស្វែងរកបទល្មើសដោយខ្លួនឯង

ការពិនិត្យស្វែងរកបទល្មើសដោយខ្លួនឯងមានន័យថា ៖ មន្ត្រីនគរបាលយុត្តិធម៌ កាលណាឃើញបទល្មើសកើតឡើង គឺគាត់មានសិទ្ធិធ្វើកិច្ចការហ្នឹងដោយខ្លួនឯងហើយ មិនចាំបាច់ប្រជាពលរដ្ឋប្ដឹងមកនោះទេ។

#### ១.២ ការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្ដឹង

ការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្ដឹងមានន័យថា គាត់អាចទទួលពាក្យបណ្ដឹង ដែលប្រជាពលរដ្ឋបានប្ដឹងមកស្ថាប័នខ្លួន ដែលបណ្ដឹងទាំងអស់ចែកចេញជា២ គឺបណ្ដឹងទាមទារ និងបណ្ដឹងបរិហារ ។

---

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៣។

តើអ្វីទៅហៅថាបណ្តឹងទាមទារ? បណ្តឹងទាមទារ គឺសំដៅទៅលើបណ្តឹង របស់ប្រជាពលរដ្ឋ ឬជាជនរងគ្រោះនៅក្នុងបទល្មើសណាមួយនោះ គាត់ប្តឹងទៅស្ថាប័នមានសមត្ថកិច្ច គឺគាត់ប្តឹងទៅនគរបាលយុត្តិធម៌ហ្នឹងតែម្តងដើម្បីទាមទារអោយស្ថាប័នមានសមត្ថកិច្ចដោះស្រាយ ឬផ្តន្ទាទោសដល់ជនល្មើស ដែលបានប្រព្រឹត្ត បទល្មើសនិងទាមទារ នូវសំណងនៃការខូចខាត ក៏ដូចជាសំណងជម្ងឺចិត្ត ដែលបាន ប្រព្រឹត្តមកលើរូបគាត់។

តើអ្វីទៅហៅថាបណ្តឹងបរិហារ? បណ្តឹងបរិហារ គឺសំដៅទៅលើបណ្តឹងរែកមុខបទល្មើស ដែលមានគោលបំណងបង្ហាញ ឬក៏បកអាក្រាតនូវបទល្មើស ដើម្បីឱ្យ ស្ថាប័នមានសមត្ថកិច្ច គាត់ជាអ្នកមានសិទ្ធិក្នុងការត្រួតពិនិត្យ និងស្វែងរកភស្តុតាងនៅក្នុងបទល្មើស ដើម្បីចាប់ជនល្មើសយកមកផ្តន្ទាទោសតាមច្បាប់។ បន្ថែមពីលើនេះទៅទៀត នៅក្នុងបណ្តឹងបរិហារអាចធ្វើឡើងជូនកាលដោយតតិយជន គឺថាជនដែលគាត់ទៅឃើញ ឬក៏គាត់បានដឹងពីបទល្មើសហ្នឹង ហើយគាត់ប្តឹងបរិហារ ទៅមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចការនេះ។ ឬក៏ជួនកាលបណ្តឹងបរិហារក៏អាចធ្វើឡើងដោយមន្ត្រីសាធារណៈដែលច្បាប់យើងបានកំណត់រួច ហើយនៅក្នុងមាត្រា ៤២ មន្ត្រីសាធារណៈមានកាតព្វកិច្ចនៅក្នុងការធ្វើបណ្តឹងបរិហារ ប្រសិនបើគាត់បានដឹងអំពីបទល្មើសណា មួយ[24]។

## កថាខណ្ឌទី២ ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង

បេសកកម្មរបស់នគរបាលយុត្តិធម៌ករណីបទល្មើសជាក់ស្តែង មានច្រើនចំណុចសំខាន់ៗដែលយើងនឹងធ្វើការបកស្រាយ ប៉ុន្តែមុននឹងធ្វើការបកស្រាយឱ្យបាន លម្អិតអំពីបេសកកម្មរបស់នគរបាលយុត្តិធម៌ចំពោះការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង ទាល់តែយើងយល់ឱ្យបានច្បាស់ជាមុនសិនថា តើអ្វីទៅជាបទល្មើសជាក់ស្តែង ?

### ២.១ និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវមូលដ្ឋាន ២ សំរាប់ធ្វើការពិនិត្យ និងកំណត់ស្ថានភាពអំពីបទល្មើសជាក់ស្តែង ដែលនគរបាលយុត្តិធម៌អាចប្រើប្រាស់ នៅក្នុងស្ថានភាពនៃការស៊ើបអង្កេតជាក់ស្តែងបាន[25]។

**ក** ៖ ក្នុងមាត្រា ៨៦ បានផ្តល់ជានិយមន័យអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ជាក់ស្តែង ។ មាត្រានេះបានចែងថា៖

**បទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងគឺ៖**

[24] កៅ សីហា, នគរបាលយុត្តិធម៌ (ភ្នំពេញ, ២០១០), ៣៨។

[25] កៅ សីហា, នគរបាលយុត្តិធម៌ (ភ្នំពេញ, ២០១០), ៤១។

១ ៖ បទល្មើសដែលកំពុងប្រព្រឹត្ត គឺបទល្មើសដែលកំពុងប្រព្រឹត្តនៅក្នុងស្ថានភាពឬនៅក្នុងអត្ថន័យ នេះអាចយល់បានថា សំដៅទៅលើស្ថានភាពមួយដូចជាជនម្នាក់កំពុងតវាយតប់គ្នា។ ដូច្នេះស្ថានភាពដែលយើងកំពុងតែឃើញគឺចាត់ទុកថា ជាស្ថានភាពដែលកំពុងប្រព្រឹត្តបទល្មើសស្របតាមសម្មតិកម្មទីមួយនេះហើយ។

២ ៖ បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាមៗ ហើយបានបញ្ជាក់បន្ថែម នៅក្នុងកថាខណ្ឌបន្ទាប់ថា ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅ ក្រោយពេលមានបទល្មើសរួចបន្តិច។ គឺស្ថានភាពដែលទើបប្រព្រឹត្តរួចភ្លាម នេះគឺអាចយល់បានថា ក្រោយពេលដែលប្រព្រឹត្តហើយភ្លាមៗតែម្តង ដូចជាគាត់បាញ់ស្លាប់នៅហ្នឹង កន្លែងតែម្តង ដូចនេះពេលដែលបាញ់គេរួចហើយ គឺបទល្មើសបានកើតមានឡើង ម្យ៉ាងទៀតគាត់មានវត្ថុមាននៅនឹងកន្លែងកើតហេតុ នេះចាត់ទុកថា ជាស្ថានភាព ដែលទើបប្រព្រឹត្តរួចភ្លាម ស្របតាមសម្មតិកម្មទីពីរនេះហើយ។

៣ ៖ ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជន ស្រែកដេញប្រដាប់ប្រភីង។ គឺក្រៅពីនេះ មាត្រា ៨៦ ក៏បានបញ្ជាក់ផងដែរថា ត្រូវចាត់ទុកថាជា បទល្មើសជាក់ស្តែងផងដែរ គឺនៅពេលដែលជនសង្ស័យត្រូវបានសាធារណជន ស្រែកដេញប្រដាប់ចាប់ប្រភីង។ ដូច្នេះស្ថានភាពនេះ វាជាក់ស្តែងណាស់ និងបញ្ជាក់យ៉ាង់ច្បាស់ថាក្នុងករណីនេះ គឺមិនអាចស្ថិតក្នុងស្ថានភាពដែលគាត់រត់ទៅឆ្ងាយ ហើយបាំងខ្លួនគាត់នោះទេ គឺយើងដេញយ៉ាងប្រកិតជាមួយជនល្មើស ហើយចាប់ជនល្មើសហ្នឹងបាននៅក្នុងស្ថានភាពនេះតែម្តង ស្ថានភាពបែបនេះគឺស្របតាមសម្មតិកម្មទីបីនេះហើយ។

៤ ៖ បុគ្គលដែលត្រូវគេរកឃើញថាមានវត្ថុ ឬមានស្នាកស្នាម ឬ តម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។ ហេតុដូច្នេះស្ថានភាព ដែលមានដូចនៅក្នុងមាត្រា ៨៦ គឺជាស្ថានភាពនៃករណីបទល្មើសជាក់ស្តែង។ នៅក្នុងករណីដែលបទល្មើសមួយប្រព្រឹត្តនៅក្នុងស្ថានភាពណាមួយ នៃស្ថានភាពដែលបានចែងនៅក្នុងមាត្រា ៨៦ នេះគឺក្នុងករណីនោះ យើងចាត់ទុកថា ជាបទល្មើសជាក់ស្តែង ហើយមន្ត្រីនគរបាលយុត្តិធម៌ គាត់អាចបើកការស៊ើបអង្កេតជាក់ស្តែងបាន។ គឺបុគ្គលដែលត្រូវបានគេរកឃើញថា មានវត្ថុ ឬមានស្លាកស្នាម ឬ តម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។

**៥** ៖ ក៏ជាលក្ខខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែងដែរ គឺមានចែងក្នុងមាត ៨៨ (ការចាត់ទុកដូចជា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ។ មាត្រានេះ បានចែង បញ្ជាក់ជូនថា ៖

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរបើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ ខាងលើនេះក៏ដោយគ្រប់បទ ឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែង ដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ

ឬភ្នាក់ងារ នគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់ មន្ត្រីនគរបាលយុត្តិធម៌។

**២.២ វិធានការស្រាវជ្រាវ**

វិធានការនេះ មានកំណត់ចាប់ពីមាត្រា ៨៩ ដល់មាត្រា ៩៥។ បើផ្អែកតាមមាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ) មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។ ដែលវិធានការទាំងនោះ យើងឃើញមានដូចខាងក្រោម ៖

**២.២.១ វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង**

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវ រាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុក នូវតម្រុយ នៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ មន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ ប្រសិនបើយល់ឃើញថា មានប្រយោជន៍ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត។ ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ធ្វើប្រតិបត្តិការលើ វិសាលភាពទាំងមូលនៃដែនដីជាតិ ដែលមានចែងក្នុងមាត្រា ដោយគោរពតាមលក្ខខណ្ឌទាំងឡាយ ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) ។

**២.២.២ ការឆែកឆេរ**

សូមបញ្ជាក់ជូនថា ការឆែកឆេរ គឺត្រូវតែគោរពឱ្យបានតឹងតែងបំផុតទៅលើលក្ខខណ្ឌ និងនីតិវិធីដែលបានចែងក្នុងមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ មាត្រានេះបញ្ជាក់ជូនថា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន តែក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌មិនចាំបាច់មានដីកាពីតុលាការទេ ប៉ុន្តែគាត់ត្រូវមានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ហើយការអនុញ្ញាតអាចធ្វើជាលាយលក្ខណ៍អក្សរ ឬមួយដោយផ្ទាល់មាត់ ដូចនេះនៅពេលដែលគាត់បានទទួលការ អនុញ្ញាតជាបឋម គឺមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដែលការឆែកឆេរ ត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដូចជា ការឆែកឆេរត្រូវធ្វើជាទូទៅនៅមុខអ្នកកាន់កាប់ទីកន្លែង ប៉ុន្តែប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ការឆែកឆេរត្រូវធ្វើនៅចំពោះ មុខសាក្សីពីររូប ដែលសាក្សីនេះត្រូវបានចាត់តាំង ដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលបានចុះដឹកនាំប្រតិបត្តិការ ។ យោងតាមគោលការណ៍ ដែលមានចែងនេះ គឺត្រូវជ្រើសរើសអ្នក ដែលមិនមានជាប់ពាក់ព័ន្ធជាមួយនឹងប្រតិបត្តិការ បានន័យថាសាក្សី មិនអាចជានគរបាលឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុង ការឆែកឆេរនោះបានឡើយ។ ដូច្នេះសាក្សីត្រូវជ្រើសរើសចេញពីអ្នក ដែលមិនបានចូលរួមក្នុងប្រតិបត្តិការនៃការឆែកឆេរនោះ។ រីឯចំណុចមួយផ្សេងទៀត

គឺទាក់ទង ទៅនឹងម៉ោងសំរាប់ធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ និង ក្រោយម៉ោង ១៨ ។ លើកលែងតែ ៖

-ក្នុងករណីដែលមានចែងដោយមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

-ក្នុងករណីដែលចែងដោយមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ឆ្នាំ ២០០៧

-ក្នុងករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង

-ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោង ដែលបើកចំហដល់សាធារណជន ។

ឧទាហរណ៍ ៖ កន្លែងដែលបើកពេលយប់មានបនពេស្យា បនល្បែង ឬ រង្គសាលរាំកំសាន្តជាដើម គឺអាចធ្វើការឆែកឆេរបាន ព្រោះគេបើកចំហរដល់សាធារណជន នៅពេលយប់ខុសពីម៉ោងឆែកឆេរចាប់ពីម៉ោង ៦ព្រឹក ដល់ ៦ល្ងាយ អាចធ្វើការឆែកឆេរ ដោយមិនចាំបាច់គោរពលក្ខខណ្ឌនៃពេលវេលាសម្រាប់ការឆែក ឆេរបាន។

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែង ដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។ នេះគឺជាវិធានពិសេសមួយ ដែលទាក់ទងទៅនឹងបទល្មើសគ្រឿងញៀន។ ករណីនេះមិនចាំបាច់គោរពវិធានទាក់ទងនឹងពេលវេលាចាប់ពីម៉ោង ៦ព្រឹក ដល់ ៦ល្ងាចឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានការអនុញ្ញាតរបស់ព្រះរាជអាជ្ញា ដោយប្រាប់ថ្ងៃនិងម៉ោងនៃការអនុញ្ញាតនេះ និងអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។

យើងសូមអនុញ្ញាតជម្រាបជូនផងដែរ អំពីលក្ខខណ្ឌពិសេសដោយមានវិជ្ជាជីវៈមួយចំនួន ដែលត្រូវគាំពារជាពិសេសដោយច្បាប់។ ដូច្នេះហើយការឆែកឆេរ ត្រូវគោរពនូវលក្ខខណ្ឌពិសេសនេះ ក្នុងនោះសំដៅដល់វិជ្ជាជីវៈពីរគឺ វិជ្ជាជីវៈមេធាវី និងវិជ្ជាជីវៈសារព័ត៌មាន។ តាមផ្លូវច្បាប់បានគាំពារដល់វិជ្ជាជីវៈទាំងនេះ ក្នុងក្របខណ្ឌនីតិវិធីព្រហ្មទណ្ឌ ដោយបានហាមឃាត់មន្ត្រីនគរបាលយុត្តិធម៌ មិនឱ្យធ្វើការឆែកឆេរចំពោះការិយាល័យមេធាវីឡើយ ។

ការឆែកឆេរអាចធ្វើបានដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ហើយការឆែកឆេរនេះ ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូប្រធានគណៈ មេធាវី ឬមេធាវីសាមី។ ដូច្នេះចំណុចនេះ ជាការការពារមួយចំពោះវិជ្ជាជីវៈមេធាវី ដែលមន្ត្រីនគរបាលយុត្តិធម៌មិនអាចបំពានបានឡើយ ម្យ៉ាងវិញទៀត គឺការពារដល់វិជ្ជាជីវៈសារព័ត៌មាន ព្រោះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយើង ក៏បានចែងការពារផងដែរ ចំពោះវិជ្ជាជីវៈសារព័ត៌មាន ទាំងសារព័ត៌មានសរសេរ ទាំងសារព័ត៌មាន សោតទស្សន៍ គឺបានន័យថា មន្ត្រីនគបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុង អគារសារព័ត៌មានដោយឯកឯងបានទេ គាត់ត្រូវធ្វើនៅចំពោះមុខព្រះរាជអាជ្ញា ឬក៏ចៅក្រមស៊ើបសួរម្នាក់។

ហេតុអ្វីចាំបាច់មានវត្តមានព្រះរាជអាជ្ញា ឬមួយចៅក្រមស៊ើបសួរម្នាក់ នៅពេលធ្វើការឆែកឆេរនៅក្នុងសហគ្រាសទាំងនោះ ? ពីព្រោះគាត់ ជាអ្នកធានារ៉ាប់រងកុំឱ្យមានការឆែកឆេរ ក្លាយទៅជាការរំលោភបំពាន ដែលនាំឱ្យមានការឃឹតឃាំងក្នុងការប្រកបវិជ្ជាជីវៈដោយសេរី នូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យឃឹតយ៉ាំងដល់ការផ្សព្វផ្សាយព័ត៌មាន ។

**ឧទាហរណ៍** ៖ មន្ត្រីនគរបាលយុត្តិធម៌ គាត់ឆែកឆេរដោយបំពាន ដោយសារគាត់ទៅឆែកឆេរការិយាល័យមេធាវី ឬអគារសារព័ត៌មានដោយឯកឯង។ ក្នុងករណីបែបនេះ ការឆែកឆេរត្រូវចាត់ទុកជាមោឃៈ បានន័យថា អ្វីដែលទទួលបាននៅក្នុងនីតិវិធីនោះ គឺមិនអាចយកជាបានការឡើយ[26]។

### ២.២.៣ ការបិទស្លាកបោះត្រាលើវត្ថុតាង

បើសិននៅក្របខណ្ឌនៃការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌បានរកឃើញ វត្ថុណាមួយដែលគួរឱ្យសង្ស័យ គាត់មានសិទ្ធិអំណាចចាប់យកវត្ថុតាងនោះបាន។ ពាក្យនេះជាពាក្យថ្មីដែលប្រើក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយើង ពាក្យថា ចាប់យកវត្ថុតាងដែលពីមុនតែងឮថា ការរឹបអូស។ ឥឡូវពាក្យនេះបានន័យថា គាត់ចាប់ផ្តើមប្រតិបត្តិការនៃការឆែកឆេរ ក៏បានរកឃើញវត្ថុតាងផ្សេងៗ ទាក់ទងនឹងបទល្មើស គាត់អាចចាប់យកវត្ថុតាងនោះបាន ក្រោយពេលដែលគាត់ចាប់យកវត្ថុតាងនោះមកហើយ គាត់ត្រូវវេចខ្ចប់ភស្តុតាងនេះទុក។ ជាទូទៅបើមើលឱ្យបានលម្អិត នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានលក្ខណៈបច្ចេកទេសខ្លាំងណាស់ មានន័យថាគាត់ត្រូវបង្ហាញសាក្សីពីរនាក់ ឬអ្នកកាន់កាប់ទីកន្លែងថា គាត់ចាប់បានភស្តុតាងនេះ ហើយគាត់បានចាប់យកទៅវេចខ្ចប់ នៅពេលដែលវេចខ្ចប់ហើយមានបិទស្លាក និង បោះត្រាដើម្បីរក្សាថា មិនមានការលួចដូរនោះឡើយ។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលដែលគាត់បញ្ចប់ប្រតិបត្តិការរបស់ខ្លួន គាត់ត្រូវធ្វើបញ្ជីសារពើភណ្ឌនៃវត្ថុ តាងទាំងឡាយដែលបានចាប់យក ហើយត្រូវភ្ជាប់ជាមួយកំណត់ហេតុនៃការឆែកឆេរមួយទៀត។ កំណត់ហេតុនៃការឆែកឆេរត្រូវកំណត់ឱ្យបានច្បាស់អំពីការអនុញ្ញាតនៅវេលាម៉ោងដែលព្រះរាជអាជ្ញាផ្តល់ការអនុញ្ញាតឱ្យ ហើយការអនុញ្ញាតអាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ កំណត់ហេតុនេះ ត្រូវចុះហត្ថលេខាដោយអ្នកចូលរួមមានន័យថា សំដៅជាពិសេសទៅដល់អ្នកកាន់កាប់ទីកន្លែងឬសាក្សី ២រូប ដែលមានវត្តមាន ហើយដាច់ខាតត្រូវតែមានគាត់ចុះហត្ថលេខា ឬ ផ្តិតម្រាមដៃ[27]។

### ២.២.៤ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស វិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូប ដែលមានមុខជំនាញឱ្យ ធ្វើការពិនិត្យផ្នែកបច្ចេកទេស និង វិទ្យាសាស្ត្រ ទៅលើភស្តុតាង

[26] កៅ សីហា, នគរបាលយុត្តិធម៌ (ភ្នំពេញ, ២០១០), ៥២។

[27] កៅ សីហា, នគរបាលយុត្តិធម៌ (ភ្នំពេញ, ២០១០), ៥២-៥៣។

ដែលគាត់ទទួលបាននោះ ដើម្បីឱ្យគាត់អាចតាមស្វែងរកភស្តុតាងបន្តទៀត។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងក្នុងមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃ អ្នកជំនាញ) នៃក្រមនីតិវិធីនេះទេ បុគ្គលនេះ ត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដោយភក្តីភាពដល់តុលាការ[28]។

**២.២.៥ ការស្តាប់ចម្លើយ និងបទបញ្ជាឱ្យចូលខ្លួន**

តើនគរបាលយុត្តិធម៌មាន វិធីសាស្ត្របែបណាខ្លះនៅក្នុងស្តាប់ចម្លើយ នៅក្នុងក្របខណ្ឌនៃការស្តាប់ចម្លើយ ក្រមនីតិវិធីព្រហ្មទណ្ឌនេះ ពុំបានបែងចែកពាក្យថា **អំណាច** ឱ្យខុសគ្នាខ្លាំងនោះទេ ព្រោះជាគោលការណ៍គឺមានអំណាចដូចគ្នា។ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែងត្រង់មាត្រា ៩៣ និង ៩៥ បានកំណត់យកនូវគោលការណ៍២ ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការងារទាក់ទងជាមួយការស្តាប់ចម្លើយ។

១ ៖ គ្រប់ការស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិកោះហៅ ដើម្បីផ្តល់ព័ត៌មាន រួចដកស្រង់យកចម្លើយ។ ដូច្នេះគ្រប់ការស្តាប់ចម្លើយ ត្រូវតែមានកំណត់ហេតុ ហើយកំណត់ហេតុនេះត្រូវបញ្ជាក់ព័ត៌មានមួយចំនួន បានន័យថា ជាព័ត៌មានដែលចាំបាច់សំខាន់ៗ ដើម្បីឱ្យអាជ្ញាធរតុលាការ ជាពិសេសខាងព្រះរាជអាជ្ញា និងចៅក្រមពិនិត្យពីនីត្យានុកូលភាព និងនិយ័តភាពនៃការស្តាប់ចម្លើយនេះ។ ការធ្វើកំណត់ហេតុនេះ ត្រូវបញ្ជាក់នូវធាតុពិត ឬការពិតនៃការឆ្លើយរបស់ជនដែលពាក់ព័ន្ធ ហើយនៅគ្រប់កំណត់ហេតុនីមួយៗ ត្រូវតែមានចុះហត្ថលេខា ឬផ្តិតស្រាមដៃរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាជនដែលពាក់ព័ន្ធ ឬអ្នកដែលត្រូវបានស្តាប់ចម្លើយ។ មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខាឬមិនព្រមផ្តិតស្រាមដៃទេមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុដូចជាសរសេរថាបានអានឱ្យស្តាប់រួចហើយ តែបុគ្គលនេះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្រាមដៃម្យ៉ាងទៀតរាល់កំណត់ហេតុទាំងឡាយណាដែលមានការឆូតលុប ក៏ត្រូវមានការចារ និងឯកភាពគ្នាដែរ។ បើក្នុងករណីអ្នកដែលបានកោះហៅមកមិនចេះភាសាខ្មែរនោះមន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែដែលបានស្បថទៅតាមសាសនា និងជំនឿរបស់ខ្លួន។

២ ៖ គ្រប់ការស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិកោះហៅជន ដែលមានផលប្រយោជន៍ដើម្បីមកបំភ្លឺ ឬផ្តល់ព័ត៌មាន។ ក្នុងករណីដែលជននោះ រឹងទទឹងដោយមិនព្រមចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិស្នើសុំទៅព្រះរាជអាជ្ញា ដើម្បីសុំឱ្យចេញបញ្ជាឱ្យចូលខ្លួន ព្រោះបញ្ជាឱ្យចូលខ្លួននេះ គឺផ្តល់សិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ឱ្យកេណ្ឌកម្លាំងសាធារណៈដែលចាំបាច់នាំខ្លួនជននេះ មកបំភ្លឺនៅចំពោះមុខមន្ត្រី

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៤។

នគរបាលយុត្តិធម៌ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង។ ដូច្នេះកិច្ចទាំងឡាយណា ដែលមិនគោរពនូវ វិធាន ដូចដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ នឹងនាំឱ្យមានមោឃភាពនូវកំណត់ហេតុរបស់នគរបាលយុត្តិធម៌ ក្នុងការស្តាប់ចម្លើយ ។

**២.៣ ការឃាត់ខ្លួន**

យើងពិនិត្យឃើញថា ការឃាត់ខ្លួននៅក្នុងការស៊ើបអង្កេតក្នុងករណីជាក់ស្តែង មានចែងចាប់ពីមាត្រា ៩៦ ដល់មាត្រា ១០២។ ដូច្នេះតើការឃាត់ខ្លួនជនណាម្នាក់ ត្រូវធ្វើទៅតាមនីតិវិធីអ្វីខ្លះ? ហើយត្រូវគោរពតាមបទដ្ឋានកម្រិតណា ចំពោះការឃាត់ខ្លួន? យើងខ្ញុំនឹងលើកយកមកបកស្រាយលម្អិតនូវចំណុចនីមួយៗដូចតទៅៈ

**២.៣.១ ល័ក្ខខ័ណ្ឌដែលត្រូវគោរពដើម្បីធ្វើការឃាត់ខ្លួន**

យោងតាមមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាច ឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ ក៏អាចឃាត់ខ្លួនបុគ្គល ដែលអាចផ្តល់ព័ត៌មានអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ បុគ្គលដែលអាចផ្តល់ព័ត៌មាន ប្រកែកមិនព្រម ផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។ យើងត្រូវពិនិត្យមើលថា ការឃាត់ខ្លួនត្រូវគោរពលើល័ក្ខខ័ណ្ឌ ២ ចំពោះការឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើសពេលនេះ ការឃាត់ខ្លួនត្រូវបានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា។ ប៉ុន្តែចំពោះបុគ្គលមួយចំនួន ដែលមន្ត្រីនគរបាលចង់បានព័ត៌មានពីគាត់ ដែលជួនកាលគាត់មិនបានប្រព្រឹត្តបទល្មើសទេ តែគាត់អាចធ្វើជាសាក្សី ដែលមន្ត្រីនគរបាលយុត្តិធម៌ចង់បានព័ត៌មានពីគាត់ បែរជាគាត់បានបដិសេធមិនព្រមផ្តល់ព័ត៌មានឡើយ។ ហេតុនេះវាចូលទៅក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៩៦ ហើយព្រោះទី១ គាត់ប្រកែកមិនព្រម ផ្តល់ព័ត៌មាន និងទី២ មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា។ ហេតុនេះទើបមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលនោះបាន។ នៅពេលដែល ឃាត់ខ្លួនបុគ្គលនោះភ្លាម មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាមដែរ មានន័យថា មិនអាចឃាត់ខ្លួនគេដោយមិនរាយការណ៍ ឬមិនជូនដំណឹងទៅ ព្រះរាជអាជ្ញានោះទេ ។

**២.៣.២ រយៈពេលនៃការឃាត់ខ្លួន**

ទាក់ទងនឹងរយៈពេលនៃការឃាត់ខ្លួននេះគឺមានចិរវេលាត ៤៨ ម៉ោងប៉ុណ្ណោះ ព្រោះនេះជាពេលវេលា ដែលច្បាប់អនុញ្ញាតតែចំពោះបទឧក្រិដ្ឋហើយ មើលទៅឃើញថា បុគ្គលដែលបានឃាត់ខ្លួននោះមានតម្រុយច្រើនបង្ហាញថាបុគ្គលនេះអាចពាក់ពន្ធ័នឹងបទឧក្រិដ្ឋ។ រយៈពេលនេះអាចសុំពន្យារបានចំនួន ២៤ម៉ោង ទៀត។ ការពន្យារពេលមិនអាចលើសពី ២៤ម៉ោងបានទេ និងត្រូវសុំការអនុញ្ញាតពី ព្រះរាជអាជ្ញាថែមទៀតផង។ នៅពេល

ដែលមានសុំការអនុញ្ញាតនេះ ព្រះរាជអាជ្ញា គាត់នឹងផ្ទៀងផ្ទាត់មើលថា តើការសុំពន្យារពេលរបស់មន្ត្រីនគរបាលយុត្តិធម៌ មានមូលហេតុសមហេតុសមផលដែរឬអត់ទេ? ក្នុងច្បាប់យើងនេះគេហៅថា ពិនិត្យមើលអំពី មូលកភាព មានន័យថា មើលទៅមានលក្ខណៈសមស្របដែរឬទេ? នេះជាចំណុចសំខាន់ មិនមែនសុំពន្យារពេលដោយចង់ទុកគេឱ្យនៅយូរនោះទេសំខាន់ទាល់តែមន្ត្រីនគរបាលយុត្តិធម៌មានតម្រុយបញ្ជាក់ថាបុគ្គលនោះមានពិរុទ្ធភាពពាក់ពន្ធ័នឹងបទល្មើសដែរ ទើបគាត់អាចសុំពន្យារពេលដើម្បីយកចំលើយបន្ថែម ទៀត ឬមួយចង់បានការស្វែងរកភស្តុតាងផ្សេងៗបន្ថែមទៀតរបស់ខ្លួន ហើយចំពោះការឃាត់ខ្លួននេះ គឺមានលក្ខណៈ ខុសៗគ្នាចំពោះបុគ្គលដែលត្រូវឃាត់ខ្លួន។ បើមនុស្សពេញវ័យ គឺចាប់ពីមានអាយុ ១៨ ឆ្នាំឡើងទៅ ការឃាត់ខ្លួនត្រូវមានរយៈពេល ៤៨ម៉ោង ហើយបទឧក្រិដ្ឋក្នុងករណីមានតម្រុយបញ្ជាក់ថា ពិតជាមានពិរុទ្ធភាពចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចសុំពន្យារពេលបាន ២៤ម៉ោង។ ផ្ទុយទៅវិញ ចំពោះអនីតិជនមិនអាចធ្វើបែបនេះបានឡើយ មានន័យថា ការពន្យារពេលមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន ។

### ២.៣.៣ ការឃាត់ខ្លួនចំពោះអនីតិជន

យើងត្រូវធ្វើការញែកចេញអនីតិជនជា ៣ ប្រភេទទៅតាមអាយុ របស់អនីតិជន ដែលត្រូវធ្វើការឃាត់ខ្លួនដែលអាយុទាំងនោះមានអាយុក្រោម ១៤ឆ្នាំ, ពី ១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ និងពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ៖

-ចំពោះអនីតិជនអាយុក្រោម ១៤ឆ្នាំ មិនអាចឃាត់ខ្លួនបានឡើយ ។

-ចំពោះអនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពី បទឧក្រិដ្ឋ មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ៦ម៉ោង ឡើយ ។

-ចំពោះអនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ៤៨ម៉ោង ឡើយ ។

-ចំពោះអនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ឡើយ ។

-ចំពោះអនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ឡើយ ។

-ចំនុចមួយទៀត ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើចំពោះការឃាត់ខ្លួន អនីតិជននោះ គឺបើកាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក-ម្តាយ អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ[29] ។

---

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០០។

### ២.៣.៤ កំណត់ហេតុស្តីពីការឃាត់ខ្លួន

នីតិវិធីនេះមានចែងក្នុងមាត្រា ៩៧ គឺការឃាត់ខ្លួនត្រូវតែធ្វើកំណត់ហេតុ ព្រោះមិនមែនចេះតែឃាត់ខ្លួនគេដោយមិនធ្វើកំណត់ហេតុនោះទេ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គល ដែលត្រូវបានឃាត់ខ្លួន ដើម្បីឱ្យគាត់បានដឹងពីមូលហេតុដែលនាំឱ្យមានការឃាត់ខ្លួនគាត់ និងត្រូវប្រាប់ឱ្យសាមីខ្លួនបានដឹងថា គាត់មានសិទ្ធិពឹងពាក់មេធាវី ដើម្បីការពារខ្លួន ដែលនេះជាប្រការមួយដើម្បីចៀសវាងនូវការរំលោភសិទ្ធិ និងផលប្រយោជន៍ ពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ ដែលបំពានទៅលើច្បាប់ និងបំពានទៅលើប្រជាជន ដែលមិនសូវចេះច្បាប់។ ក្នុងករណីចាំបាច់ចំពោះការយកចំលើយផ្សេងៗ បើជនដែលត្រូវបានឃាត់ខ្លួនជាជនបរទេសដែលគាត់មិនអាចស្តាប់យល់ភាសាខ្មែរបាននោះដូច្នេះគាត់មានសិទ្ធិសុំឱ្យ ឬអ្នកជាប់ពាក់ព័ន្ធនឹង ប្រតិបត្តិការឡើយ។ រីឯកំណត់ហេតុឃាត់ខ្លួនតើត្រូវមានចុះនិទ្ទេសអ្វីខ្លះ? មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ដោយមានចុះសេចក្តីដូចតទៅ ៖

-ឈ្មោះ និង ឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន

-ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តិនៃមាត្រា៩៨ (ជួយជំនួសមេធាវីនៅក្នុងពេលឃាត់ខ្លួន)

ការកំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួចឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានកំណត់ហេតុអោយស្តាប់។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសហើយកុំភ្លេចថាកំណត់ហេតុនេះត្រូវភ្ជាប់ទៅជាមួយនឹងសំណុំរឿងនេះផងដែរ ។

**ចំណាំ** ៖ ហេតុអ្វីបានជាក្រមនេះបានចែងថា អោយជនដែលត្រូវឃាត់ខ្លួនផ្តិតម្រាមដៃ? ព្រោះខ្លាចថាពេលខ្លះគាត់អត់មានមេដៃដោយសារតែគាត់ពិការ មេដៃពីកំណើត ឬពិការដោយឧប្បត្តិហេតុណាមួយដូច្នេះគាត់នៅមានតែម្រាមដៃ តើឱ្យគាត់ផ្តិតមេដៃម៉េចនឹងកើតទៅ? នេះហើយគឺជាគោលការណ៍ ដែលបើកទូលាយក្នុងការអនុវត្ត ។

### ២.៣.៥ កំណត់ហេតុសរុបនៃការឃាត់ខ្លួន

គេបានបង្កើតអោយមានកំណត់ហេតុសរុបនៃការឃាត់ខ្លួនមួយដើម្បី ឱ្យគ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ។ កំណត់ហេតុ សរុបនេះត្រូវមានចុះនិទ្ទេសដូចតទៅ ៖

-ឈ្មោះ និង ឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមការឃាត់ខ្លួន

-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

-បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០ អនីតិជន ដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

-អត្តសញ្ញាណរបស់ជន ដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួន ស្រប តាមមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឱ្យបន្ត ការឃាត់ខ្លួន

-ចិរវេលានៃការស្តាប់ចម្លើយនីមួយៗនិងចិរវេលានៃការសម្រាក នៅចន្លោះការស្តាប់ចម្លើយនីមួយៗ

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការ នៅពេលបញ្ចប់ការឃាត់ខ្លួន

-លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ ។

-កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង[30] ។

**២.៤ ការបញ្ជូនខ្លួន**

យើងបានដឹងហើយថារយៈពេលនៃការឃាត់ខ្លួនគឺអាចឈានទៅដល់ ៤៨ម៉ោង ទោះបីរយៈពេលដែលច្បាប់អនុញ្ញាតជាអតិប្បរមាគឺ ៤៨ម៉ោង ហើយបើបទឧក្រិដ្ឋដែលយល់ឃើញថាមានតម្រុយអាចពន្យាបាន ២៤ម៉ោងនេះគ្រាន់តែជារយៈពេលអតិប្បរមា មិនមែនកំណត់ថាទាល់តែផុត ៤៨ម៉ោងបានបញ្ជូនខ្លួនគេទៅនោះទេ។មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់តែ ៥ម៉ោង ឬតិចជាងពេលនេះ គាត់បញ្ជូនទៅព្រះរាជអាជ្ញាក៏បានដែរ ព្រោះនៅពេលដែលផុតរយៈពេលនេះ គឺគាត់ត្រូវតែបញ្ជូនបុគ្គលដែលឃាត់ខ្លួននោះទៅព្រះរាជអាជ្ញាភ្លាមតែម្តង។ ដូច្នេះមិនមែនមានន័យថា ឱ្យតែគ្រប់ការឃាត់ខ្លួន ទាល់តែគ្រប់រយៈពេលនេះចាំបញ្ជូនគេទៅនោះទេ។ ដោយមូលហេតុនេះហើយ ទើបពាក់ព័ន្ធនឹងការបញ្ជូនខ្លួននេះ យើងត្រូវពិនិត្យចំណុច ២ ដូចខាងក្រោម៖

**២.៤.១ ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន**

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ហើយប្រសិនបើគាត់មើលទៅឃើញថាវាមិនមានអ្វីធ្ងន់ធ្ងរ ព្រះរាជអាជ្ញាអាចមិនបញ្ជូនខ្លួនជននោះទៅឱ្យចៅក្រម

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០២។

ស៊ើបសួរទៀតទេ គាត់អាចបន្តនីតិវិធីរបស់គាត់ ប៉ុន្តែដោះលែងបុគ្គលនោះឱ្យត្រឡប់មកផ្ទះ ដើម្បីមានសេរីភាពដូចដើមឡើងវិញ។ សេចក្តីសម្រេចនេះ ធ្វើឡើងដោយព្រះរាជអាជ្ញាមានន័យថា អាចសម្រេចបញ្ជូនទៅចៅក្រមស៊ើបសួរ ឬដោះលែងឱ្យមានសេរីភាពវិញ[31] ។

**២.៤.២ រយៈពេលនៃការបញ្ជូនខ្លួន**

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួនត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញានោះ បុគ្គលនេះ ត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូនដូចជារថយន្តបែកង់អស់សាំង ឬក៏ចម្ងាយផ្លូវនៃការដឹកជញ្ជូននោះឆ្ងាយរយៈពេលបន្ថែមអាច ផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន។ នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះក្នុងកំណត់ហេតុនូវមូលហេតុនៃការយឺតយ៉ាវ ហើយត្រូវប្រគល់ជូនព្រះរាជអាជ្ញា[32] ។

**២.៥ វិធានទាក់ទងទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែង**

វិធានទាំងនេះ មានចែងចាប់ពីមាត្រា ១០៥ ដល់ មាត្រា ១១០ ដូចការពន្យល់លម្អិតខាងក្រោម ៖

**២.៥.១ ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង**

ការស៊ើបអង្កេតបទល្មើសជាក់ស្តែងមានថិរវេលាមិនអាចលើសពី ៧ថ្ងៃបានឡើយ បើគិតពីថ្ងៃប្រព្រឹត្តបទល្មើស។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលា ៧ថ្ងៃនេះ ហើយប្រសិនបើការស៊ើបអង្កេត មិនបានបញ្ចប់នៅក្នុងរយៈពេល ៧ថ្ងៃនេះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំ យោបល់ទៅព្រះរាជអាជ្ញា ថាតើគួរធ្វើបែបណាទៀតចំពោះសំណុំរឿងនេះ? ពេលនោះព្រះរាជអាជ្ញាគាត់នឹងឆ្លើយតបថាគួរធ្វើបែបណាជាក់ជាមិនខានឡើយ[33]។

**២.៥.២ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញានិងនិទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ**

ក្រោយបិទបញ្ចប់ការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។ បើបុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញានោះ ការបញ្ជូនកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះផងដែរ។

កំណត់ហេតុ ដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសដូចតទៅ ៖

---

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០៣។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០៤។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០៦។

-ឈ្មោះ និង ឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនោះ

-កាលបរិច្ឆេទ ។

កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួន ត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ ហើយទំព័រនីមួយៗត្រូវចុះហត្ថលេខា ដោយមន្ត្រីនគរបាលយុត្តិធម៌។ ប្រសិនបើមានពាក្យឆូតលុប និងការយោង ត្រូវមានបញ្ជាក់ថា យល់ព្រមដោយមានការចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ[34]។

ឧទាហរណ៍ ៖ យល់ព្រមឱ្យលុបពាក្យថា ក ដោយកដាក់ថា ខ វិញ និងចុះហត្ថលេខា។កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានធម្មតាប៉ុណ្ណោះ។ ប៉ុន្តែកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវទុកជាបន្ទាល់ឯកសារដើម មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។ ភស្តុតាងផ្ទុយអាចជូនទៅចៅក្រមបានដោយសេរី តាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់។

**ចំណាំ** ៖ ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ចៅក្រមធ្វើមូលវិចារណ៍ ដោយសេរីលើកំណត់ហេតុ ដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌[35] ។

### ២.៥.៣ ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯខជាអាទិ៍

នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះ ត្រង់មាត នឹងមាត្រា ១៨៣ ក្នុងដំណាក់កាលនៃការស៊ើបសួរ ព្រោះមាត្រា ១០៥ នេះ មិនបានចែងផ្តល់សិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ ដូចការផ្តល់សិទ្ធិអំណាចនៅក្នុងមាត្រា ១៨៣ នៃក្រមនីតិវិធីនេះទេ។ មាត្រា ១០៥ ចែងថា"មន្ត្រីនគរបាល ពុំមានអំណាចបង្គាប់ឱ្យស្តាប់និងថតសំលេងការសន្ទនាតាមទូរស័ព្ទឡើយ នឹងមន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លង ដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរស័ព្ទ ឬសារតាមអ៊ិនធើណេតឡើយ។

### ២.៥.៤ មោឃភាពនៃការមិនគោរព វិធានបញ្ញត្តិ

វិធាន និងទម្រង់ការដែលបានបញ្ញត្តនៅក្នុង ៖

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)

-មាត្រា ៩១ (ការឆែកឆេរ)

-មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)

-មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)

-មាត្រា ៩៤ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)

---

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០៧ និងមាត្រា ១០៨។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១០។

-មាត្រា ៩៥ (ការឃាត់ខ្លួន)

-មាត្រា ៩៧ (កំណត់ហេតុស្ដីពីការឃាត់ខ្លួន)

-មាត្រា ៩៨ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)

-មាត្រា ៩៩ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)

-មាត្រា ១០០ (ការហាមឃាត់មិនឱ្យស្លាប់ដោយឯកឯងជាអាទិ៍)

-មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្ដែង)

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនីតិវិធីនេះ។ មានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នេះទេមាត្រា ១០៩ នេះនឹងនាំឱ្យមាននូវមោឃភាពនៃនីតិវិធី មានន័យថានីតិវិធីដែលបានធ្វើហើយនោះនឹងត្រូវទុក ជាអសារបង់។

**កថាខណ្ឌទី៣ ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្ដែង**

ក្រៅពីការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ នៅក្នុងករណីបទល្មើសជាក់ស្ដែងគាត់ក៏អាចធ្វើការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្ដែងបានដែរ តែត្រូវគោរពនូវនីតិវិធីមួយចំនួនដូចខាងក្រោម ៖

**៣.១ អត្ថន័យបទល្មើសមិនជាក់ស្ដែង**

នៅក្នុងករណីនៃការស៊ើបអង្កេតបឋម ឬការស៊ើបអង្កេតក្នុងករណីមិនជាក់ស្ដែងមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តទៅតាមគោលការណ៍ ដែលមានចែងឱ្យក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា១១១ ដល់មាត្រា១១៨។ សូមជម្រាបជូនថាអំណាចនៅក្នុងការស៊ើបអង្កេតបឋមនេះ គឺខុសពីអំណាចក្នុងការស៊ើបអង្កេតករណីជាក់ស្ដែងដែលយើងនឹងលើកយកមកបង្ហាញដូចតទៅ ៖

**៣.១.១ ការបើកការស៊ើបអង្កេតបឋម**

ទាក់ទងនឹងការបើកការស៊ើបអង្កេតបឋម មានភាពខុសគ្នាទៅនឹងការបើកការស៊ើបអង្កេតករណីជាក់ស្ដែងដូចមានចែងក្នុងមាត្រា ១១១ ថាកាលណា បានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។

**៣.១.២ វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម**

ចំពោះវិធានដែលត្រូវអនុវត្តនៅក្នុងករណីស៊ើបអង្កេតបឋម យើងសង្កេតឃើញថា មិនសូវជាខុសគ្នាប៉ុន្មាននោះទេ ទាក់ទងទៅនឹងការស៊ើបអង្កេតករណីជាក់ស្ដែងព្រោះមាត្រា ១១២ បានបញ្ជាក់យ៉ាងច្បាស់ថាបទប្បញ្ញត្តិនៃមាត្រាមួយចំនួន ដែលមានចែងនៅក្នុងការស៊ើបអង្កេតករណីបទល្មើសជាក់ស្ដែង ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋមដែរ ។ ចំពោះមាត្រាទាំងនោះរួមមាន៖

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)

-មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍)

-មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) ។

សូមបញ្ជាក់ថា ដោយសារតែវិធានទាំងនេះយើងបានបកស្រាយយ៉ាងលម្អិតរួចមកហើយ នៅក្នុងការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែង ហេតុដូច្នេះ ដើម្បីមានភាពច្បាស់លាស់ យើងខ្ញុំលើកឡើងនូវចំណុចដែលពាក់ព័ន្ធនឹងមាត្រាទាំង ៥ នេះ ដូចមាននៅក្នុងការបកស្រាយខាងលើ។

**៣.១.៣ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ**

ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម វិធាន និងទម្រង់ការ ដែលចែង នៅក្នុងមាត្រា ៖

-មាត្រា ៩៦ (ការឃាត់ខ្លួន)

-មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)

-មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)

- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្លាប់ដោយឯកឯងជាអាទិ៍)

-មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)

-មាត្រា ១១៣ (ការឆែកឆេរ)

-មាត្រា ១១៤ (ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម) នៃក្រមនីតិវិធីព្រហ្មទណ្ឌមានលក្ខណដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នេះទេ មាត្រា ១១៧ នេះនឹងនាំឱ្យមានមោឃភាពនៃនីតិវិធីមានន័យថា នីតិវិធីដែលបានធ្វើហើយនោះ នឹង ត្រូវទុកជាឥតបានការ។

**៣.២ ការឆែកឆេរ**

ការឆែកឆេរនៅក្នុងការស៊ើបអង្កេតបឋម ថ្វីត្បិតតែមានចំណុចមួយចំនួនដូចគ្នា ទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែងផ្ទុយទៅវិញ ក៏មានចំណុច មួយចំនួនមិនដូចគ្នាដែរទាក់ទងនឹងបែបបទដែលត្រូវគោរព ចំណុចដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពគឺមានដូចតទៅ ៖

កាលណាការស៊ើបអង្កេតបឋមនោះទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង។ ជាបឋមមន្ត្រីនគរបាលយុត្តិធម៌ ត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ដែលការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែង នោះមិនចេះអក្សរទេ ក៏ប៉ុន្តែយល់ព្រមឱ្យឆែកឆេរ ក្នុង

ករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬមួយបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា ហើយព្រះ រាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខ អ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ ត្រូវធ្វើនៅចំពោះមុខសាក្សី ០២ នាក់។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការ ក្នុងការឆែកឆេរនោះឡើយ។ ការឆែកឆេរមិនអាចចាប់ផ្ដើមធ្វើនៅមុនម៉ោង ៦ និង ក្រោយម៉ោង ១៨ ឡើយ។ បទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនេះត្រូវយកមកអនុវត្តក្នុងការចាប់យកវត្ថុតាង[36] ។

**៣.៣ ការបញ្ជាឱ្យចូលខ្លួន**

បញ្ជាឱ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតបឋម ត្រូវយកមកអនុវត្តដូចគ្នា នឹងបញ្ជាឱ្យចូលខ្លួនក្នុងករណីនៃការស៊ើបអង្កេតករណីជាក់ស្ដែង។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា ១១៤ ស្ដីពី "ការបញ្ជាឱ្យចូលខ្លួន" បានកំណត់យ៉ាងច្បាស់ណាស់ថា៖ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្ដាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថា បានចូលរួមក្នុងបទល្មើស ឬដែលអាចផ្ដល់ព័ត៌មានស្ដីពីរឿងហេតុ។ បុគ្គលដែលកោះហៅត្រូវតែចូលមកបង្ហាញខ្លួន។ ក្នុងករណីដែលបុគ្គលនោះរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួន បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានចុះអត្តសញ្ញាណបុគ្គលពាក់ព័ន្ធកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង។ បញ្ជាឱ្យចូលខ្លួននេះ អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន ។

**៣.៤ ការឃាត់ខ្លួនជនជាប់សង្ស័យ**

យោងតាមមាត្រា ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បញ្ជាក់ថា "កាលណាការស៊ើបអង្កេតបឋមទាក់ទងទៅនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ បទប្បញ្ញត្តិនៃជំពូកទី ៣ ស្ដីពី ការឃាត់ខ្លួន និង ជំពូកទី ៤ ស្ដីពីការបញ្ជូនខ្លួន នៃមាតិកាទី ២ ស្ដីពីការស៊ើបអង្កេតករណីជាក់ស្ដែង ក្នុងគន្ថីទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ ត្រូវយកមកអនុវត្តដូចគ្នា អាស្រ័យហេតុនេះ អត្ថន័យដែលបានបកស្រាយយ៉ាងលម្អិតរួចហើយ ដូចមានក្នុងការស៊ើបអង្កេតករណីជាក់ស្ដែងខាងលើ ត្រូវយកមកពិភាក្សា ឬធ្វើការសិក្សាដូចគ្នាទាក់ទងនឹងការឃាត់ខ្លួនជនជាប់សង្ស័យ ក្នុងការស៊ើបអង្កេតបឋម ។

**៣.៥ កំណត់ហេតុក្នុងការស្ដាប់ចម្លើយ**

រាល់ការស្ដាប់ចម្លើយទាំងឡាយ ដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ គឺចាំបាច់ត្រូវតែគោរពឱ្យបានត្រឹមត្រូវតាមមាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្ដីពី (កំណត់ហេតុស្រង់យកចម្លើយនៅក្នុងការស៊ើបអង្កេតបឋម)។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១៣។

មាត្រា ១១៥ បាន ចែងច្បាស់ថា "ការស្តាប់ចម្លើយនីមួយៗត្រូវមានធ្វើកំណត់ហេតុ ហើយកំណត់ហេតុត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលដែលពាក់ព័ន្ធ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែ ដែលបានស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថា រូបខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ។

## ផ្នែកទី២ នៅក្នុងដំណាក់កាលស៊ើបសួរស៊ើបសួរ

ក្រោយពីបានសិក្សាអំពីបេសកកម្មរបស់នគរបាលយុត្តិធម៌ នៅក្នុងដំណាក់កាល នៃការស៊ើបអង្កេតរួចមកឥឡូវនេះ យើងនឹងឈានទៅធ្វើការសិក្សា អំពីបេសកកម្មរបស់នគរបាលយុត្តិធម៌នៅក្នុង ដំណាក់កាលនៃការស៊ើបសួរវិញម្តងក្នុងផ្នែកនេះយើងនឹងពិភាក្សាអំពី (កថាខណ្ឌ១) សិទ្ធិអំណាចតាមរយៈដីការចាត់ឱ្យស៊ើបសួរជំនួស (កថាខណ្ឌ២) កាតព្វកិច្ចនៅក្នុងដំណាក់កាលនៃការស៊ើបសួរ (កថាខណ្ឌ៣) កិច្ចដែលត្រូវហាមឃាត់ចំពោះមន្ត្រីនគរបាលយុត្តិធម៌ ដូចការលើកឡើងខាងក្រោម ៖

### កថាខណ្ឌទី១ សិទ្ធិអំណាចតាមរយៈដីកា ចាត់ឱ្យស៊ើបសួរជំនួស

យោងតាមមាត្រា ១៣១ និង ១៧៣ ចែងអំពី "ដីកាចាត់ឱ្យស៊ើបសួរជំនួស បានផ្តល់សិទ្ធិអំណាចឱ្យទៅមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចមួយចំនួនជំនួសឱ្យចៅក្រមស៊ើបសួរតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលមានចែងនៅក្នុងមាត្រា ១៧៨ (កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យ) ដល់មាត្រា ១៨៤ (កំណត់ ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនីតិវិធីនេះ។ ចំពោះការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមនេះតែប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។ កំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវតែស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ។ ដូច្នេះកិច្ចទាំងឡាយ ដែលមានដូចខាងក្រោមនេះ មន្ត្រីនគរបាលយុត្តិធម៌អាចមានសិទ្ធិអំណាចទៅបានទាល់តែមានដីកាចាត់ឱ្យស៊ើបសួរជំនួស[37] ។

---

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៧៤។

**១.១ សិទ្ធិអំណាចនៅក្នុងការស្តាប់ដោយឯកឯងជាអាទិ៍**

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោយបាយទូរគមនាគមន៍ ដូចជាសារតាមទូរសារ ឬសារតាមអ៊ិនធើណែត មន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់អំណាច ដែលប្រគល់ឱ្យខ្លួនដោយចៅក្រមស៊ើបសួរ តាមរយៈវាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ១៧២ (ការស្តាប់ទូរស័ព្ទជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមនេះ ដែលក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ បានចែងថា "ចៅក្រមស៊ើបសួរ ក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យោយបាយទូរគមនាគមន៍ផងដែរ ដូចជាសារតាមទូរសារ ឬសារតាមអ៊ិនណែត។" និងកថាខណ្ឌទី ២ បានចែងថា "ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីប្រភេទនៃទំនាក់ទំនង ដែលត្រូវចាប់ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម។" ក្នុងបរិបទខាងលើ បានអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌យកសិទ្ធិអំណាចទាំងអស់នោះមកប្រើប្រាស់បាន[38] ។

**ចំណាំ** ៖ នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែង ពិសេសត្រង់មាត្រា ១០៥ និងករណីបទល្មើសមិនជាក់ស្តែង ដែលបានចង្អុលបង្ហាញ ក្នុងមាត្រា ១១២ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍ បានចែងថា "មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យស្តាប់ និងថតសំលេងការសន្ទនា តាមទូរស័ព្ទឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លង ដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរសារ ឬ សារតាមអ៊ិនធើណែតឡើយ។" នេះសបញ្ជាក់ឱ្យឃើញថាអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ខុសពីគ្នា ឬក៏អំណាចប្រែប្រួលទៅតាមដំណាក់កាលនីមួយៗ នៃកិច្ចនីតិ វិធីព្រហ្មទណ្ឌ[39] ។

**១.២ សិទ្ធិអំណាចនៅក្នុងការកោះហៅ និងស្តាប់ចម្លើយសាក្សី**

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សីបាន។ មុននឹងឆ្លើយចំពោះសំណួរសាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថាតែការពិត។ ក៏ប៉ុន្តែសាក្សីដែលមានរៀបរាប់នៅមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាត ឱ្យរួចពីសម្បថ ត្រូវបានលើកលែងមិនចាំបាច់ធ្វើសម្បថទេ ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ កាលណាការស្តាប់ ចម្លើយសាក្សីណាម្នាក់បាន ធ្វើឱ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សី

---

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨៣។

[39] កៅ សីហា, នគរបាលយុត្តិធម៌ (ភ្នំពេញ, ២០១០), ៧៧។

នោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ។ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ដែលបានស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថា រូបខ្លួននឹងជួយបកប្រែជូនតុលាការឱ្យបានត្រឹមត្រូវ។ បុគ្គលដែល បានកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែចូលបង្ហាញខ្លួន។ បើក្នុងករណីរឹងទទឹងមន្ត្រី នគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ដែលអាចចេញបញ្ជាឱ្យចូលខ្លួនដោយមានចុះអត្តសញ្ញាណនៃសាក្សី បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ បញ្ជាឱ្យចូលបង្ហាញខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំឱ្យសាក្សី ចូលបង្ហាញខ្លួនចំពោះមុខខ្លួន។ កថាខណ្ឌទី២ ដល់ កថាខណ្ឌទី៥ នៃមាត្រា៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនីតិវិធីនេះត្រូវយកមកអនុវត្តលើកំណត់ ហេតុស្តីពីការស្តាប់ចម្លើយសាក្សី[40]។

### ១.៣ សិទ្ធិអំណាចនៅក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង

មាត្រា ១៨១ នៃក្រមនីតិវិធីនេះបានបង្ហាញថា មន្ត្រីនគរបាលយុត្តិធម៌អាច ធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង នៅក្នុងលក្ខខណ្ឌដូចដែលមានចែងនៅក្នុងមាត្រា៩១ (ការឆែកឆេរ) និងមាត្រា៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)នៃក្រមនេះ។ ប៉ុន្តែការអនុញ្ញាត ដែលមានចែងនៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី១ នៃមាត្រា៩១ ស្តីអំពី(ការឆែកឆេរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះ ត្រូវតែផ្តល់ឱ្យដោយចៅក្រមស៊ើបសួរ តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។

### ១.៤ សិទ្ធិអំណាចនៅក្នុងការឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិអំណាចពេញលេញ តាមបទប្បញ្ញត្តិនៃមាត៩៦ (ការឃាត់ខ្លួន) ដល់មាត្រា ១០២ (កំណត់ហេតុសរុបនៃការឃាត់ខ្លួន) ស្តីពី "ការឃាត់ខ្លួន ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ក៏ប៉ុន្តែអំណាចដែលប្រគល់ឱ្យដោយមាត្រាទាំងនេះ ដល់ព្រះរាជអាជ្ញាត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរសម្រាប់ការអនុម័ត បញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន និងមាត្រា ១០៣ ដល់ ១០៤(រយៈពេលនៃការបញ្ជូនខ្លួន)នៃក្រមនេះ នៅពេលផុតកំណត់នៃការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែនាំជន ដែលត្រូវបានឃាត់ខ្លួនទៅបង្ហាញខ្លួន នៅចំពោះមុខចៅក្រមស៊ើបសួរ[41] ។

## កថាខណ្ឌ២ ភាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលការស៊ើបសួរ

បន្ទាប់ពីបានយល់អំពីសិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលនៃការស៊ើបសួររួចហើយ បន្តទៅទៀតនេះ យើងនឹងព្យាយាមលើកយកមក បង្ហាញអំពីកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ដូចការពន្យល់ខាងក្រោម ៖

---

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៧៩។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨២។

**២.១ ការរក្សាការសំងាត់នៃការស៊ើបសួរ**

ការស៊ើបសួរត្រូវតែជាការសម្ងាត់។ យោងតាមមាត្រា ១២១ នៃក្រមនីតិវិធីនេះ មានបុគ្គលជាច្រើនអាចចូលរួមក្នុងការស៊ើបសួរ ដែលក្នុងនោះក៏ឃើញមាន នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការសាធារណៈ ដែលបុគ្គលខ្លះទទួលបាននូវ នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ចូលរួមក្នុងការស៊ើបសួរផងដែរ។ ដូច្នេះ នគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបសួរនោះ ត្រូវតែរក្សាការសម្ងាត់ វិជ្ជាជីវៈរបស់ខ្លួន។ ប៉ុន្តែការគោរពផ្លូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។ ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺ ជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌជាធរមាន[42] ។

**២.២ ការចាប់បង្ខំទៅលើសាក្សីឱ្យចូលបង្ហាញខ្លួន**

នៅពេលដែលបុគ្គលគ្រប់រូប ត្រូវបានចៅក្រមស៊ើបសួរកោះហៅ ក្នុងឋានៈជាសាក្សី ពេលនោះគេត្រូវតែចូលមកបង្ហាញខ្លួនតាមការកោះហៅ។ ផ្ទុយទៅវិញ បើមិនចូលមកបង្ហាញខ្លួនតាមការកោះហៅនោះទេមានន័យថាក្នុងករណីដែលរឹងទទឹងនោះ ចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈ ដែលក្នុងនោះក៏អាចមានមន្ត្រីនគរបាលយុត្តិធម៌ដែរ ដើម្បីបង្ខំសាក្សីនេះឱ្យចូលមកបង្ហាញខ្លួនបាន។ ដូច្នេះនៅពេលដែលមានការស្នើសុំពីចៅក្រមស៊ើបសួររួចមក មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនទៅតាមការស្នើសុំនោះ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែចាប់បង្ខំទៅលើសាក្សី ដែល រឹងទទឹងនោះ ឱ្យចូលមកបង្ហាញខ្លួននៅចំពោះ មុខចៅក្រមស៊ើបសួរ តាមការស្នើសុំរបស់គាត់[43]។

**២.៣ ការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួន**

ផ្អែកលើមាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ កំណត់ថា មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងអំពី ដីកាបង្គាប់ឱ្យចូលខ្លួន[44] ដល់បុគ្គលដែលពាក់ព័ន្ធ។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកាហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលទៅចៅក្រមស៊ើបសួរវិញ។ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្ម របស់ខ្លួន។

ឧទាហរណ៍ ៖ លោក ក ជាមន្ត្រីនគរបាលយុត្តិធម៌ គាត់យកដីកាបង្គាប់ឱ្យ ចូលខ្លួនទៅជូនលោក ខ ដែលជាជនត្រូវចោទ ឬជាជនដែលមានតម្រុយពិរុទ្ធភាពនៅ ឯផ្ទះលោក ខ ផ្ទុយទៅវិញ នៅពេលដែលទៅដល់ផ្ទះលោក ខ បែរជាមិនជួប ព្រោះគ្មានបុគ្គលណាម្នាក់នៅក្នុងផ្ទះនោះសោះ។ អង្គហេតុនេះ គឺជាការលំបាកក្នុង ការអនុវត្តបេសកកម្មរបស់ខ្លួន ដូច្នេះគាត់ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរឱ្យ បានដឹងពីបញ្ហាលំបាកនេះ។

---

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១២១។

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៥៣។

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៦។

**២.៤. ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន**

បើយោងតាមមាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ថា ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនត្រូវប្រគល់ទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ហើយដើមដីកានេះ ត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ។ មន្ត្រីនគរបាលយុត្តិធម៌ ក៏ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួនពាក់ព័ន្ធនឹងដីកា បង្គាប់ឱ្យនាំខ្លួនដូចដីកាបង្គាប់ឱ្យចូលខ្លួនដែរ[45]។

**២.៥ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន**

យោងតាមមាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ថា ការអនុវត្តដីកា បង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ករណីបន្ទាន់ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាននគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុត ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវឱ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន ដូចដីកាបង្គាប់ឱ្យចូលខ្លួន និងដីកាបង្គាប់ឱ្យនាំខ្លួនដែរ[46] ។

**ចំណាំ** ៖ នៅក្នុងការអនុវត្តដីកាទាំងដីកាបង្គាប់ឱ្យនាំខ្លួន ទាំងដីកាបង្គាប់ឱ្យចាប់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌គាត់មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានឡើយព្រោះផ្អែកតាមផ្លូវច្បាប់នៅចន្លោះម៉ោងខាងលើនេះ គឺជាម៉ោងនីត្យានុកូល។

**២.៦ ការអនុវត្តដីកាកោះហៅ ឬដីកាផ្សេងៗទៀត**

គ្រប់មន្ត្រីរាជការសាធារណៈ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់នគរបាល ឬកងរាជអាវុធហត្ថ ដែលបុគ្គលខ្លះគាត់ទទួលបាននូវនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬជាភ្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវបានចៅក្រមស៊ើបសួរ សុំឱ្យប្រគល់ដីកាកោះហៅ ឬដីកាផ្សេងៗទៀត ត្រូវតែអនុវត្តតាមបញ្ជារបស់ចៅក្រមនេះ។ បុគ្គល ឬអង្គភាព ឬអាជ្ញាធរដែលចៅក្រមស៊ើបសួរចាត់តាំងនោះ ត្រូវតែប្រគល់ដីកាកោះ ឬដីកាដល់សាមីខ្លួនដោយមានចំណាររបស់អ្នកទទួលបញ្ជាក់ថា បានទទួលទុកជាសម្គាល់។ ដីកាដែលមានចំណារទទួលនេះ ត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួររយៈពេលយ៉ាងខ្លីបំផុត [47]។

---

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៦។

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៦។ ចែងថា ដីការបង្គាប់ឱ្យចាប់ខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះ ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងឃុំខ្លួនបុគ្គលនោះ។

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២៣៩។

**ចំណាំ** ៖ មិនមែនគ្រប់មន្ត្រីរាជការសាធារណៈ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់ នគរបាល ឬកងរាជអាវុធហត្ថ សុទ្ធសឹងតែជានគរបាលយុត្តិធម៌នោះទេ ដោយសារ តែយើងកំពុងសិក្សាលើនគរបាលយុត្តិធម៌ងពី ដូច្នេះហើយ ទើបយើងលើកយកពួកគាត់មកធ្វើការពិភាក្សា។ ផ្ទុយទៅវិញ ចៅក្រមស៊ើបសួរ ក៏អាចប្រើអ្នក ដែលមិន មែនជាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឱ្យអនុវត្តនូវការប្រគល់ ដីកានេះបានដែរ[48]។

## កថាខណ្ឌ៣ សមត្ថកិច្ចដែនដី និងកិច្ចដែលត្រូវហាមឃាត់ចំពោះមន្ត្រីនគបាលយុត្តិធម៌

នៅចំណុចនេះ យើងនឹងធ្វើការពន្យល់២ ចំណុចផ្សេងដាច់ពីគ្នារវាងចំណុច (សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌) និង (កិច្ចដែលត្រូវហាមឃាត់ចំពោះមន្ត្រីនគរបាលយុត្តិធម៌)។

### ៣.១ សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ គឺដូចគ្នាទាំងស្រុងទៅនឹងសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងដំណាក់កាលនៃការស៊ើបអង្កេតដូចមានឃើញចែងនៅក្នុងមាត្រា ៦៧ និងមាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដោយសារតែមាត្រា ១៧៧ នៃក្រមនីតិវិធីនេះនិយាយពីការប្រតិបត្តិដីកាចាត់ឱ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ដូចដែលបានចែងថា "មន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ច ដែលមានចែងនៅក្នុងដីកាចាត់ ឱ្យស៊ើបសួរជំនួស នៅក្នុងសមត្ថកិច្ចផែនដីរបស់ខ្លួន លើកលែងតែបទប្បញ្ញត្តិនៃ កថាខណ្ឌទី២ និងទី៣ នៃមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះចេញ" ។ យោងតាមអត្ថន័យនេះ ហើយទើបយើងធ្វើការបែងចែកចេញជា ២ ចំណុចគឺ (**គោលការណ៍**) និង (**អញ្ញត្រកម្ម**) ដូចខាងក្រោម ៖

#### ៣.១.១ គោលការណ៍

ជាគោលការណ៍ដូចដែលមានកំណត់ត្រង់មាត្រា ៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្ដីពី (មណ្ឌលរដ្ឋបាលបំពេញការងារ)បានចែងយ៉ាងច្បាស់ថា "មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាព ដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅមប្រើការងារ។ ដោយឡែកនៅរាជធានីភ្នំពេញមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃរាជធានីទាំងមូល បើទោះបីជាអង្គភាពដែល ខ្លួនផ្លាស់ទៅកាន់នោះនៅទីកន្លែងណាក៏ដោយ។ សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែបញ្ជាក់ពីមណ្ឌលរដ្ឋបាល ដែលមន្ត្រីនោះត្រូវចាត់តាំងឱ្យទៅបម្រើការងារនេះ។ សេចក្តីសម្រេច តែងតាំងត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍" ។

---

[48] កៅ សីហា, នគរបាលយុត្តិធម៌ (ភ្នំពេញ, ២០១០), ៨៣-៨៤។

### ៣.១.២ អញ្ញត្រកម្ម

ជាទូទៅឱ្យតែមានគោលការណ៍ តែងតែមានអញ្ញត្រកម្មដែលអញ្ញត្រកម្ម នេះ មានន័យថា ជាករណីលើកលែង ឬជាករណីពិសេស ។ ជាក់ស្តែងជាអញ្ញត្រកម្ម ទៅលើគោលការណ៍ខាងលើ សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌អាចត្រូវ បានពន្លាតបានន័យថា មន្ត្រីនគរបាលយុត្តិធម៌អាចមានសិទ្ធិអំណាចធំធេងជាងសិទ្ធិអំណាច ដែលមានចែងនៅក្នុងមាត្រា ៦៧ ពាក់ព័ន្ធនឹងការបំពេញបេសកកម្មរបស់ ។ តើនៅពេលណា ទើបមានការពន្លាតសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌? ហើយត្រូវគោរពនូវល័ក្ខខ័ណ្ឌអ្វីខ្លះ? បើផ្អែកតាមមាត្រា ៦៨ នៃក្រមនីតិវិធី ព្រហ្មទណ្ឌស្តីពី "ការពន្លាតសមត្ថកិច្ចដែនដី" បានចែងយ៉ាងច្បាស់ថា "ក្នុងករណីបទឧក្រិដ្ឋ ឬបទបជ្ឈិមជាក់ស្តែង តាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទ មជ្ឈិមជាក់ស្តែង) និងមាត្រា ៨៧ (ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ ហើយប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល។

ការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់បាន ក៏ប៉ុន្តែការអនុញ្ញាតនេះ ត្រូវតែចុះនិទ្ទេសនៅក្នុង លិខិតស៊ើបអង្កេត។ ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញ ដីកាចាត់ឱ្យស៊ើបសួរជំនួសនៅក្នុងករណីបន្ទាន់ ដូច្នេះចៅក្រមនេះ អាចអនុញ្ញាតឱ្យ មន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល។ បើកាលណាគាត់ធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចខាងដែនដី ហើយចៅក្រុម ដែលបានអនុញ្ញាតឱ្យមានការពន្លាតសមត្ថកិច្ច ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី" ។

**ចំណាំ** ៖ មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ត្រូវទទួលបញ្ជា ឬសុំបញ្ជាតែពីអាជ្ញាធរតុលាការមួយប៉ុណ្ណោះ។ ចំណែកឯវិធាននៃ សមត្ថកិច្ចខាងដែនដី ដែលបានបញ្ញត្តនៅក្នុងមាត្រាមុនៗគឺមាត្រា ១៧៧ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ និងមាត្រា ៦៧ និង ៦៨ នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតមានលក្ខណៈដាច់ខាត បើមិនគោរពតាមទេនោះ កិច្ចទាំងឡាយណា ដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវទុកជាមោឃៈ[49] ។

## ៣.២ កិច្ចដែលត្រូវហាមឃាត់ចំពោះមន្ត្រីនគរបាលយុត្តិធម៌

ក្រៅពីសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌នេះ យើងក៏ត្រូវយល់ដែរថា តើមានចំណុចណាខ្លះទៅដែលត្រូវបានហាមឃាត់ចំពោះការបំពេញបេសកកម្ម របស់មន្ត្រីនគរបាលយុត្តិធម៌? កិច្ចដែលត្រូវហាមឃាត់ទាំងអស់នោះរួមមាន[50]៖

---

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៩ និងមាត្រា ៧០។

[50] កៅ សីហា, នគរបាលយុត្តិធម៌ (ភ្នំពេញ, ២០១០), ៨៧។

**៣.២.១ ការបកប្រែភាសាបរទេស**

យោងតាមមាត្រា ១៤៤ ស្តីពី "ជំនួយរបស់អ្នកបកប្រែ" បានហាមយ៉ាង ដាច់ខាតថា ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថឡើយ ទោះបីជាខ្លួនទទួលបាននូវនីតិសម្បទាជា មន្ត្រីនគរបាលយុត្តិធម៌ក៏ដោយ ។ សូមបញ្ជាក់ថា មាត្រានេះក៏មិនខុសពីមាត្រា នៃដំណាក់កាលនៃការស៊ើបអង្កេតដែរ ព្រោះមាត្រានោះក៏បានហាមដែរថា អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថបានឡើយ។ និងមិនខុសពីមាត្រា ៣៣០ នៃដំណាក់កាលនៃការជំនុំជម្រះឡើយ ពីព្រោះ មាត្រានេះ ក៏បានហាមដែរថា នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថទេ។

**៣.២.២ ការធ្វើជាសាក្សីនៅក្នុងការឆែកឆេរ**

យោងតាមមាត្រា ១៥៩ ស្តីពី "វិធានអនុវត្តចំពោះការឆែកឆេរ" គឺបាន ហាមយ៉ាងដាច់ខាតថា សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជា កងកម្លាំង រួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ទោះជាគាត់គឺជាមន្ត្រីនគរបាលយុត្តិធម៌ក៏ដោយ។ សូមបញ្ជាក់ថា មាត្រានេះក៏មិនខុសពីមាត្រា ៩១ ក្នុងដំណាក់កាលនៃការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែងនិងមាត្រា ១១៣ ក្នុងដំណាក់កាលនៃការស៊ើបអង្កេតករណីបទល្មើសមិនជាក់ស្តែងផងដែរ ពីព្រោះមាត្រា ទាំងនោះបានហាមថា សាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជា កងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

**៣.២.៣ ការសួរចម្លើយជនត្រូវចោទ និងស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

មាត្រា ១៨០ ស្តីពី "ការស្តាប់ចម្លើយ ដែលពុំអាចធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌" ក៏បានហាមដែរថា មន្ត្រីនគរបាលយុត្តិធម៌មិនអាចសួរចម្លើយជនត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ។ សូមបញ្ជាក់ថា មាត្រានេះ ខុសពី មាត្រា ៩៣ ក្នុងដំណាក់កាលនៃការស៊ើបអង្កេត ពីព្រោះមាត្រានោះមិនឃើញមានចែងហាមឃាត់ ពាក់ព័ន្ធទៅនឹងចំនុចនៃការសួរចម្លើយ និងស្តាប់ចម្លើយនេះទេ ។

## ផ្នែកទី៣ មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលជំនុំជម្រះ និងនីតិវិធីផ្សេងទៀត

នៅក្នុងដំណាក់កាលនៃការជំនុំជម្រះនេះ យើងនឹងលើកយកនូវបេសកកម្មនៅក្នុង ៣ (បី) ដំណាក់កាលមកធ្វើការពិភាក្សាគឺ ទី១-ដំណាក់កាលនៃសាលាដំបូងរាជធានី-ខេត្ត), ទី២-ដំណាក់កាលនៃសាលាឧទ្ធរណ៍ និងទី៣-ដំណាក់កាលនៃតុលាការកំពូល។ ដើម្បីយល់ឱ្យបានលម្អិត សូមពិនិត្យលើដំណាក់កាលនីមួយៗដូចតទៅ ៖

### កថាខណ្ឌ១ បេសកកម្មនៅក្នុងដំណាក់កាលនៃសាលាដំបូងរាជធានី-ខេត្ត

បេសកកម្មនៅក្នុងដំណាក់កាលនៃសាលាដំបូងរាជធានី-ខេត្ត ដូចមានចែងចាប់ពីមាត្រា ២៨៧ ដល់មាត្រា ៣៧២ ដែលបេសកកម្មរបស់នគរបាលយុត្តិធម៌ ទាំងនោះ ឃើញមានកំណត់នៅក្នុងមាត្រាមួយចំនួនដូចខាងក្រោម ៖

### ១.១ ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់[51] អាចត្រូវបានប្រគល់តាមរយៈ វិធីមួយចំនួនដូចមានចែងក្នុងមាត្រា ៤៦៣ ស្ដីពី "របៀបផ្សេងទៀតនៃការប្រគល់ដី កាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់" ឆ្លងតាមរយៈមួយមាត្រានេះ នគរបាលយុត្តិធម៌ ក៏ត្រូវមានបេសកកម្មនៅក្នុងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែរ ប្រសិនបើគេប្រើវិធីប្រគល់តាមរយៈអង្គភាពនគរបាល កងរាជអាវុធហត្ថ ឬតាមផ្លូវរដ្ឋបាល។ ដូច្នេះអាជ្ញាធររដ្ឋបាលមន្ត្រីនគរបាលជាតិ ឬមន្ត្រីនៃកងអាវុធហត្ថ ដែលអាចជាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវ គ្មានព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវតែគោរព តាមបញ្ជារបស់ព្រះរាជអាជ្ញា និងត្រូវបំពេញកិច្ចនេះដូចមានចែងនៅក្នុងមាត្រា ៤៦០ (ការប្រគល់ចុងដីកាកោះហៅ ដោយអាជ្ញាសាលាដល់ជនជាប់ចោទ) ដល់មាត្រា ៩៦២ (ការប្រគល់ចុងដីកាកោះហៅ ដោយអាជ្ញាសាលាដល់មេឃុំ ឬចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ១.២ ការអមជនជាប់ចោទនៅក្នុងនីតិវិធីចូលបង្ហាញខ្លួនភ្លាម

នៅក្នុងករណីនីតិវិធីចូលបង្ហាញខ្លួនភ្លាម បើផ្អែកទៅលើមាត្រា៣០៣ ស្ដីពី (ការបង្ហាញខ្លួនរបស់ជនជាប់ចោទដោយមានកងកម្លាំងអម) និងមាត្រា៣០៤ ស្ដីពី (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានសបញ្ជាក់ឱ្យយើងដឹងថា ជនជាប់ចោទត្រូវឃុំគ្រងដោយកងការពាររហូតដល់សាមីខ្លួន ចូលបង្ហាញ ខ្លួននៅចំពោះមុខសវនាការ ដែលការបង្ហាញខ្លួននោះត្រូវប្រព្រឹត្តទៅនៅក្នុងថ្ងៃនោះតែម្ដង។ ដូច្នេះពាក្យថា កងការពារនៅក្នុងមាត្រាទាំងនេះ អាចសំដៅទៅរកស្ថាប័ន នគរបាលយុត្តិធម៌ ដែលមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ គឺជាអ្នកបំពេញបេសកកម្មនៅក្នុងការអមជនជាប់ចោទ ដើម្បីយកទៅចូលបង្ហាញខ្លួនចំពោះមុខសវនាការ ឬចៅក្រមជំនុំជម្រះ ។

### ១.៣ ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ

នៅក្នុងរឿងមជ្ឈិម និងឧក្រិដ្ឋ ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួន តុលាការអាចបង្គាប់ឱ្យបង្អង់រឿងនេះទុកសិន និងឱ្យចេញដីកាបង្គាប់ឱ្យនាំខ្លួន។ ហើយតុលាការត្រូវតែយកបទប្បញ្ញត្តិត្រង់មាត្រា ១៩២ នាំខ្លួននៃក្រមនីតិវិធីនេះមកអនុវត្ត។ (ការអនុវត្តដីកាបង្គាប់ ឱ្យពេលនោះនគរបាលយុត្តិធម៌ត្រូវបំពេញបេសកកម្មរបស់ខ្លួនដូចមានចែងត្រង់មាត្រា១៩២ក្នុងដំណាក់កាលនៃការស៊ើបសួរ។ ដូច្នេះនៅពេលដែលនគរបាលយុត្តិធម៌បានទៅនាំខ្លួនជនជាប់ចោទមករួចហើយ ជនជាប់ចោទត្រូវបាននាំខ្លួនទៅកាន់អង្គភាពនគរបាល ឬកង

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៥៦ ចែងថា ដីការកោះហៅបញ្ជូនទៅជំនុំជំរះផ្ទាល់ គឺជាបញ្ជាដល់ជនជាប់ចោទ ឱ្យចូលមកបង្ហាញខ្លួននៅតុលាការជាន់ដំបូង ដែលសម្រេចពីរឿងព្រហ្មទណ្ឌ។

រាជអាវុធហត្ថ ឬ មណ្ឌលឃុំខ្លួន ឬពន្ធនាគារ ដើម្បីរក្សាទុកជាមុន រហូតដល់ពេលជនជាប់ចោទនេះ ចូលបង្ហាញខ្លួននៅមុខតុលាការ[52] ។

**១.៤ ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនតាមរយៈដីកាបញ្ជូន**

ក្នុងករណីដែលតុលាការទទួលបណ្តឹង តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ពេលនោះជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី លើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឱ្យឃុំខ្លួន បណ្តោះអាសន្ន។ ក្នុងករណីខាងក្រោយនេះ កងកម្លាំងសាធារណៈអាចជាមន្ត្រីនគរបាលយុត្តិធម៌ ឬមួយភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវអនុវត្តតាមរយៈដីកាបញ្ជូន ឬតាម រយៈសាលដីកាបញ្ជូននេះ មានន័យថា ត្រូវនាំខ្លួនជនជាប់ចោទ ដែលត្រូវបានឃុំខ្លួននោះ ទៅកាន់សវនាការតាមការចាត់វិធានការចាំបាច់របស់ព្រះរាជអាជ្ញា[53] ។

**១.៥ ការបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួន**

ក្នុងករណីរឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួនតាមការកោះហៅរបស់តុលាការ ពេលនោះតុលាការអាចប្រើវិធីសាស្ត្រមួយ គឺប្រើកងកម្លាំងសាធារណៈដែលក្នុងនោះ អាចជាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ដើម្បីទៅបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួន ព្រោះសាក្សីត្រូវតែចូលមកបង្ហាញខ្លួននៅមុខតុលាការតាមការកោះហៅ[54] ។

**១.៦ ការធ្វើជាសាក្សីរបស់នគរបាលយុត្តិធម៌**

ដោយហេតុថា មាត្រា៣២៦ ស្តីពី (ការស្តាប់ចម្លើយរបស់ភាគី) ត្រង់ ទី ២ នៃកថាខណ្ឌទី ១ បានចែងថា "ប្រធានសវនាការអាចស្តាប់នូវវាក្យខណ្ឌ ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួម ក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី។" បើយោងតាមអត្ថន័យនេះឃើញថា មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ក៏អាចធ្វើជាសាក្សីបាននៅចំពោះមុខចៅក្រមជំនុំជម្រះ នៅក្នុងពេលបើកសវនាការដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ។

**១.៧ ការធានាសណ្តាប់ធ្នាប់នៃសវនាការ**

ជាការពិត ប្រធានសវនាការជាអ្នកដើរតួនាទីយ៉ាងសំខាន់ ចំពោះការធានារ៉ាប់រង ឱ្យមានសណ្តាប់ធ្នាប់ល្អនៅក្នុងពេលសវនាការ ឬក្នុងពេលធ្វើការជំនុំជំរះរឿងក្តីម្តងៗ មានន័យថា មិនមែនជាសមត្ថកិច្ចរបស់នគរបាលយុត្តិធម៌នោះទេតែផ្ទុយទៅវិញ នគរបាលយុត្តិធម៌ គឺជាជំនួយឱ្យស្ថាប័នតុលាការនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

---

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣១០។

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣០៥។

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣១៥។

ហេតុនេះ នៅក្នុងការបំពេញមុខងាររបស់ខ្លួន ប្រធានសវនាការអាចប្រើប្រាស់កងកម្លាំងសាធារណៈ ដូចបាន លើកឡើងហើយថា អាចជាមន្ត្រីនគរបាលយុត្តិធម៌ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ ដើម្បីឱ្យជួយសម្រួលដល់ការ ធានាសណ្តាប់ធ្នាប់ល្អ សវនាការនេះបាន[55] ។

### ១.៨ ការជូនដំណឹងអំពីដីកាសម្រេចរបស់តុលាការ

ការជូនដំណឹងអំពីដីកាសម្រេចរបស់តុលាការ អាចប្រគល់ឱ្យដោយក្រឡាបញ្ជី ឬប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទ ដទៃទៀត ។ មិនតែប៉ុណ្ណោះ ក៏អាចប្រគល់ឱ្យតាមរយៈផ្លូវ រដ្ឋបាល ឬអង្គភាពនគរបាល ឬកងរាជអាវុធហត្ថបានដែរ។ ដូច្នេះប្រសិនបើតុលាការជ្រើសរើសតាមរយៈ វិធីខាង ក្រោយនេះ អាជ្ញាធររដ្ឋបាល ឬមន្ត្រីនគរបាលជាតិ ឬមន្ត្រីនៃកងអាវុធហត្ថ ហើយក្នុងន័យនេះ យើងសំដៅយក នគរបាលយុត្តិធម៌ ដែលព្រះរាជអាជ្ញាសុំឱ្យជូនដំណឹងពីសេចក្តីសម្រេចរបស់តុលាការ ត្រូវតែបំពេញបេសកកម្ម របស់ខ្លួន (ដោយគោរពទៅតាមបញ្ជារបស់ព្រះរាជអាជ្ញា ហើយកិច្ចបែបនេះ ត្រូវធ្វើដូចមានចែងនៅ ក្នុងមាត្រា៤៨៦ (ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចជូនដល់ភាគី ដែលពាក់ព័ន្ធដោយអាជ្ញាសាលា) រហូតដល់មាត្រា ៤៨៨ (ការប្រគល់លិខិតចម្លង នៃសេចក្តី សម្រេចដល់មេឃុំ ឬចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរថ្មី[56]។

### ១.៩ ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ គឺមិនមែនធ្វើត្រឹមតែនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលបានប្រកាសសាលក្រម ឬនៅចំពោះមុខប្រធាន ពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឬធ្វើនៅចំពោះមុខព្រះរាជ អាជ្ញានោះទេ ។ បណ្តឹងទាស់ចំពោះសាលក្រមប្រភេទនេះ ក៏អាចធ្វើបានដែរនៅឯអង្គភាពនគរបាល ឬកងរាជ អាវុធហត្ថ ដែលភាគច្រើនសំដៅទៅដល់អង្គភាពនគរបាលយុត្តិធម៌ ។ បើកាលណាអង្គភាពនគរបាលយុត្តិធម៌ បានទទួលពាក្យបណ្តឹងទាស់នេះរួចរាល់ហើយ បុគ្គលដែលបម្រើការក្នុងអង្គភាពនេះ ត្រូវបញ្ជូនបណ្តឹងទាស់ នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការ ដែលបានប្រកាសសាលក្រម[57] ។

**ចំណាំ** ៖ បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខនេះដាច់ខាតត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។

## កថាខណ្ឌ២-បេសកកម្មនៅក្នុងដំណាក់កាលនៃសាលាឧទ្ធរណ៍

ក្រៅពីបេកកម្មក្នុងដំណាក់កាលនៃសាលាដំបូងរាជធានី-ខេត្ត នគរបាលយុត្តិធម៌ក៏មានបេសកកម្មសំខាន់ មួយចំនួនក្នុងដំណាក់កាលនៃសាលាឧទ្ធរណ៍ផងដែរ។ ចំពោះនីតិវិធីព្រហ្មទណ្ឌក្នុងដំណាក់កាលនៃសាលា ឧទ្ធរណ៍ត្រូវបានកំណត់ចាប់ពីមាត្រា ៣៧៣ ដល់មាត្រា ៤១៦។ មន្ត្រីនគរបាលយុត្តិធម៌ ក្នុងដំណាក់កាលនៃ

---

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣១៨។

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៨៩។

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣៦៦។

សាលាឧទ្ធរណ៍ មាននូវបេសកកម្មសំខាន់មួយចំនួនដូចជា ការទទួលពាក្យបណ្ដឹងទាស់ចំពោះសាលដីកាកំបាំងមុខ ការបញ្ជូនពាក្យបណ្ដឹងទាស់ចំពោះសាលដីកាកំបាំងមុខ និងការប្រគល់ដីកាកោះហៅ។ អាស្រ័យហេតុនេះ យើងនឹងព្យាយាមលើកយកមកបង្ហាញ នូវបេសកកម្មទាំងឡាយណារបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលមានចែងពាក់ព័ន្ធនៅក្នុងដំណាក់កាលនៃសាលាឧទ្ធរណ៍នេះ មកបកស្រាយជូនដូចខាងក្រោម ៖

**២.១ ការទទួលពាក្យបណ្ដឹងទាស់ចំពោះសាលដីកាកំបាំងមុខ**

បណ្ដឹងទាស់ចំពោះសាលដីកាកំបាំងមុខ គឺមិនមែនធ្វើត្រឹមតែនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានសម្រេចចេញសាលដីកា ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឬធ្វើនៅចំពោះមុខអគ្គព្រះរាជអាជ្ញានោះទេ។ បណ្ដឹងទាស់ចំពោះសាលដីកាប្រភេទនេះ ក៏អាចធ្វើបានដែរនៅឯអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលភាគច្រើនបំផុតសំដៅទៅដល់អង្គភាពនគរបាលយុត្តិធម៌។ ដូច្នេះនៅពេលដែលមានការធ្វើបណ្ដឹងទាស់ចំពោះសាលដីកាកំបាំងមុខនេះ ជាលាយលក្ខណ៍អក្សរ ហើយដាក់ជូនមកអង្គភាពរបស់ខ្លួន ពេលនោះមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវតែទទួលពាក្យបណ្ដឹងនេះទុក ដើម្បីចាត់ការទៅតាម នីតិវិធីបន្តទៀត ។

**២.២ ការបញ្ជូនពាក្យបណ្ដឹងទាស់ចំពោះសាលដីកាកំបាំងមុខ**

នៅពេលដែលមានការធ្វើបណ្ដឹងទាស់ ចំពោះសាលដីកាកំបាំងមុខនេះ ជាលាយលក្ខណ៍អក្សរ ហើយដាក់មកអង្គភាពរបស់ខ្លួន បើកាលណាអង្គភាពនគរបាលយុត្តិធម៌ បានទទួលពាក្យបណ្ដឹងទាស់នេះរួចរាល់ហើយ ដូច្នេះដើម្បីចាត់ការទៅតាមនីតិវិធីបន្តទៀត បុគ្គលដែលបានបម្រើការក្នុងអង្គភាពនោះ ត្រូវបញ្ជូនបណ្ដឹងម្ចាស់នោះភ្លាមទៅក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានប្រកាសចេញសាលដីកា[58]។

**២.៣ ការប្រគល់ដីកាកោះហៅ**

នៅក្នុងដំណាក់កាលនៃសាលាឧទ្ធរណ៍ ដីកាកោះហៅគឺអាចត្រូវបាន ប្រគល់តាមរយៈវិធីមួយចំនួនដូចមានចែងក្នុងមាត្រា ៤៧២ ស្ដីពី (របៀបផ្សេងទៀត ការប្រគល់ដីកាកោះហៅ) ។ ឆ្លងតាមរយៈមាត្រានេះ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវ មានបេសកកម្មនៅក្នុងការប្រគល់ដីកាកោះហៅដែរ ប្រសិនបើតុលាការប្រើវិធីប្រគល់ដីកានេះតាមរយៈអង្គភាពនគរបាល កងរាជអាវុធហត្ថ ឬតាមផ្លូវរដ្ឋបាល។ ដូច្នេះអាជ្ញាធររដ្ឋបាល មន្ត្រីនគរបាលជាតិ ឬមន្ត្រីនៃកងរាជអាវុធហត្ថ ដែលជាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវបានព្រះរាជអាជ្ញាសុំ ឱ្យប្រគល់ដីកាកោះហៅ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា និងត្រូវបំពេញកិច្ចនេះដូចមានចែងនៅក្នុងមាត្រា ៤៦៩ (ការប្រគល់ចុងដីកាដោយអាជ្ញាសាលាដល់ ជនជាប់ចោទ) ដល់មាត្រា ៤៧១ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលា ដល់មេឃុំ ឬចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤១០។

**កថាខណ្ឌ៣-បេសកកម្មនៅក្នុងដំណាក់កាលនតុលាការកំពូល**

ក្រោយពីធ្វើការពិនិត្យលើដំណាក់កាលនៃតុលាការកំពូល ចាប់ពីមាត្រា៤១៧ ដល់មាត្រា៤៥៥ យើងឃើញថា បេសកកម្មរបស់នគរបាលយុត្តិធម៌ មាន ចែងតែក្នុងមួយមាត្រាប៉ុណ្ណោះគឺ ៖

**៣.១ ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការចំពោះគូភាគី**

ប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃសវនាការនេះ ហើយអគ្គព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងអំពីកាលបរិច្ឆេទនេះដល់ភាគី និងមេធាវី ។ ការឱ្យដំណឹងដល់ ជនជាប់ចោទ ដែលជាប់ឃុំដល់ពិរុទ្ធជន ដែលឃុំខ្លួន ឬដល់បុគ្គល ដែលគេទាមទារនៅក្នុងរឿងបត្យាប័ន ត្រូវធ្វើឡើងតាមរបៀបដូចជា ៖ ដោយផ្ទាល់មាត់ ឬតាមរយៈ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ចំណែកឯការឱ្យដំណឹងទៅពិរុទ្ធជន ឬជនជាប់ចោទនៅក្រៅឃុំ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងដល់មេធាវីត្រូវធ្វើដូចតទៅ៖ ដោយផ្ទាល់មាត់ តាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ កាលណាការឱ្យដំណឹងត្រូវធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះ និទ្ទេសអំពីកាលបរិច្ឆេទនៃការឱ្យដំណឹងទៅលើសំណុំរឿង ពិរុទ្ធជន ជនជាប់ ចោទដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬមេធាវីចុះហត្ថលេខា របស់ខ្លួន នៅក្នុងករណីដទៃទៀត ការឱ្យដំណឹងត្រូវធ្វើដោយមានបង្កាន់ដៃបញ្ជាក់ថា បានទទួលសម្រាប់ទុកជាសម្គាល់។ ឆ្លងតាមរយៈអត្ថន័យខាងលើនេះ បង្ហាញឱ្យឃើញថា មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក៏ត្រូវបំពេញបេសកកម្មពាក់ព័ន្ធនឹងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការចំពោះភាគីនេះដែរ[59] ។

**កថាខណ្ឌ៤ បេសកកម្មរបស់នគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលផ្សេងទៀត**

នីតិវិធីមួយចំនួនផ្សេងទៀត នៅក្នុងដំណាក់កាលមួយនេះ យើងនឹងធ្វើការពិចារណាទៅលើបេសកកម្មរបស់នគរបាលយុត្តធម៌នៅក្នុង ដំណាក់កាលនៃនីតិវិធីប្រតិបត្តិ (ចំណុច ៤.១ និងដំណាក់កាល នៃនីតិវិធីដោយឡែក (ចំណុច ៤.២ )

**៤.១ បេសកកម្មនៅក្នុងដំណាក់កាលនៃនីតិវិធីប្រតិបត្តិ**

ដំណាក់កាលនេះមានចែងចាប់ពីមាត្រា៤៩៦ ដល់ មាត្រា៥៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំណែកឯបេសកកម្មរបស់នគរបាលយុត្តិធម៌មានចែងតនៅក្នុង មាត្រាមួយចំនួនប៉ុណ្ណោះ ។

**៤.១.១. ការធានារ៉ាប់រងនូវការអនុវត្តទោស**

ដើម្បីធានារ៉ាប់រងនូវការអនុវត្តទោសបើផ្អែកលើមាត្រា៤៩៩ ស្ដីពីការសុំកងកម្លាំងសាធារណៈ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានប្រគល់ជូនដល់អគ្គព្រះរាជ អាជ្ញាអមតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ

---

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៣៣។

ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត នូវសិទ្ធិអំណាចក្នុងការសុំកងកម្លាំងសាធារណៈដូចជាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ជាដើម ដើម្បីទៅបំពេញបេសកកម្ម ក្នុងការអនុវត្តទោស នៅពេលដែលមានសេចក្តីសម្រេច (សាលក្រម ឬសាលដីកា) ជាស្ថាពរពីតុលាការឱ្យផ្តន្ទាទោសជនណាម្នាក់។

**៤.១.២ ការស្នើសុំពិនិត្យមើលបញ្ជីជនជាប់ឃុំ**

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បំពេញភារកិច្ច តាមការប្រគល់សិទ្ធិអំណាច ពីអាជ្ញាធរតុលាការស្នើសុំពិនិត្យមើលបញ្ជីជនជាប់ឃុំគ្រប់ភ្នាក់ងារនៃរដ្ឋបាលពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវតែជូនបញ្ជីនេះទៅបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលបំពេញបេសកកម្មនោះ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌អាចសុំពិនិត្យមើលបញ្ជីជនជាប់ឃុំបាន ព្រោះគ្រប់ពន្ធនាគារ និងមណ្ឌលឃុំខ្លួនទាំងអស់ ត្រូវមានបញ្ជីមួយដែលចុះនិទ្ទេសអំពីអត្តសញ្ញាណបុគ្គលឃុំខ្លួន កាលបរិច្ឆេទ ឃុំខ្លួន និង កាលបរិច្ឆេទដោះលែង[60]។

**៤.១.៣ ការស្នើសុំឱ្យបង្ហាញខ្លួនជនជាប់ឃុំ**

យោងតាមមាត្រា៥០៨ ស្តីពី ការបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំ) បានឱ្យដឹងថា គ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ត្រូវតែបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបំពេញភារកិច្ចតាមការប្រគល់អំណាចពី អាជ្ញាធរតុលាការ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌អាចសុំឱ្យបង្ហាញខ្លួនជនជាប់ឃុំបាន។

**៤.១.៤ ការជូនដំណឹងស្តីពីការបង្ខំដល់រូបកាយ**

ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូងរាជធានី-ខេត្ត ។ ក្រោយមកព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិតដើម្បីបង់ប្រាក់នោះហើយឱ្យដំណឹងក្នុងរយៈពេលមិនអាចតិចជាង ។ ១០ (ដប់) ថ្ងៃទេ ដោយត្រូវបញ្ជាក់ប្រាប់ថាប្រសិនបើមិនបង់ទេនោះ សាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ។ ដូច្នេះដើម្បីឱ្យសាមីខ្លួនអាចទទួលព័ត៌មាននេះបានទាល់តែធ្វើការឱ្យដំណឹងដល់គាត់ ដែលការផ្តល់ដំណឹងត្រូវធ្វើដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលចំណុចទាំងនេះ ច្រើនតែសំដៅទៅដល់អង្គភាពនគរបាល យុត្តិធម៌ មានន័យថា ជាអង្គភាពសំខាន់មួយ ជំនួយឱ្យស្ថាប័នតុលាការ ក្នុងការជូនដំណឹងផ្សេងៗ ជាក់ស្តែងគឺការជូនដំណឹង ស្តីពីការបង្ខំដល់រូបកាយនេះឯង[61]។

---

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥០៥។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥២៤។

### ៤.១.៥ ការចាប់ និងឃុំខ្លួនទណ្ឌិតក្នុងករណីនៃការបង្ខំដល់រូបកាយ

លុះដល់ផុតរយៈពេលកំណត់ ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធី ឬប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី នោះទេព្រះរាជអាជ្ញាអាចចេញបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួនបាន ពីព្រោះការមិនព្រមបង់ប្រាក់ទាំងអស់នេះ គឺជាលក្ខខណ្ឌនៃការបង្ខំដល់រូបកាយ ដូចមានកំណត់ក្នុងមាត្រា៥២៣ ដូច្នេះដើម្បីសម្រេចកិច្ចការនេះ ព្រះរាជអាជ្ញាត្រូវសុំឱ្យកម្លាំងសាធារណៈចាប់ និងឃុំខ្លួនទណ្ឌិត ដូចបានពន្យល់រួចមកហើយថាកម្លាំងសាធារណៈ ក៏រួមមាននគរបាលយុត្តិធម៌នៅក្នុងនោះដែរ។អាស្រ័យហេតុនេះហើយ ពួកគេត្រូវតែបំពេញបេសកកម្មរបស់ខ្លួន ក្នុងវិស័យយុត្តិធម៌ដើម្បីចាប់ និងឃុំខ្លួនទណ្ឌិតតាមការសុំរបស់ព្រះរាជអាជ្ញា ។

**ចំណាំ** ៖ ដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពនៃសុខភាព របស់ទណ្ឌិត ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបាន ដូច្នេះនៅពេលដែល ព្រះរាជអាជ្ញាបង្អង់សេចក្តីសម្រេចនេះហើយ នគរបាលយុត្តិធម៌ត្រូវផ្អាកបេសកកម្ម របស់ខ្លួនផងដែរ[62]។

### ៤.២ បេសកកម្មនៅក្នុងដំណាក់កាលនៃនីតិវិធីដោយឡែក

នៅក្នុងនីតិវិធីដោយឡែកបេសកកម្មរបស់នគរបាលយុត្តិធម៌ ជាការរក្សាទុកនូវលិខិតនីតិវិធី ដោយផ្អែកតាមបញ្ញត្តិដែលមានចែងចាប់ពីមាត្រា៥៥៥ ដល់មាត្រា៦០៦ យោងតាមរយៈការស្រាវជ្រាវឃើញថា មានចំណុចមួយដែលពាក់ព័ន្ធនឹងនគរបាលយុត្តិធម៌នោះ គឺលិខិតនៃនីតិវិធីត្រូវបង្កឡើងវិញ តាមលិខិតចម្លងដែលរក្សាទុកដោយអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ភាគីអ្នកជំនាញ ក្រឡាបញ្ជី ឬបុគ្គលផ្សេងទៀត[63]។ ឆ្លងតាមអត្ថន័យនេះឃើញថា លិខិតនៃនីតិវិធីត្រូវបានរក្សាទុកនៅកន្លែងផ្សេងៗគ្នា ដែលក្នុងនោះក៏រួមមាននគរបាលយុត្តិធម៌ផងដែរមានន័យថាស្ថាប័នដែលជួយស្វែងរកយុត្តិធម៌មួយនេះត្រូវរក្សាទុកនូវលិខិតនៃនីតិវិធីដើម្បីងាយស្រួលពេលបាត់បង់លិខិតចម្លងឬបើនិយាយសាមញ្ញគេហៅថាចុងសន្លឹកនោះទើបខ្លួនអាចបង្កឡើងវិញនូវលិខិតចម្លងថ្មីទៅតាមលិខិត ដែលរក្សាទុកនៅឯអង្គភាពរបស់ខ្លួនបាន ។

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥២៦។

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦០៥។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌គឺពិតជាដំណាក់កាលមួយក៏សំខាន់ ព្រោះនគរបាលយុត្តិធម៌ គឺជាជំនួយការរបស់អំណាចតុលាការ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង។ ព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្រប សម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តដីកាចាត់ចែងឱ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌដាក់នគរបាលយុត្តិធម៌ស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ ។

បេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានគោលដៅវែកមុខរកជនដែលបានប្រព្រឹត្តបទល្មើស និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ព្រមទាំងសង្គមជាតិ។ មន្ត្រីនគរបាលមិនត្រូវរំលងនូវនីតិវិធីសាកសួរជនសង្ស័យ និងសាក្សីឡើយ ព្រោះវាក៏ជាសញ្ញាមួយដែលអាចឱ្យមន្ត្រីនគរបាលធ្វើការកំណត់អត្តសញ្ញាណជនដែលប្រព្រឹត្តបទល្មើស។ ក្រោយពីស្វែងរកភស្តុតាងដែលបានបន្សល់ ទុកនៅកន្លែងកើតហេតុ ការសម្ភាសន៍ជនសង្ស័យ និងសាក្សីហើយនោះ ប្រសិនបើមានភាពស៊ីសង្វាក់គ្នា ពេលនោះមន្ត្រីនគរបាលអាចចាត់វិធានការតាមស្វែងរកចាប់ខ្លួន ជនដែលបានប្រព្រឹត្តបទល្មើស ដោយមានសេចក្តីសម្រេចពីព្រះរាជអាជ្ញា ឬដោយមានដីកាចាប់ខ្លួនផងដែរ។ នៅក្នុងការស៊ើបែអង្កេតបទល្មើសព្រហ្មទណ្ឌណាមួយវា គឺជាសកម្មភាពដ៏សកម្ម ឬក៏ជាបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌។

នៅក្នុងដំណើរការស៊ើបអង្កេតបទល្មើសនីមួយៗ មន្ត្រីអាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ដោយគ្រាន់តែមានតម្រុយមួយចំនួន ឬទទួលពាក្យបណ្តឹងពីជនរងគ្រោះផ្ទាល់ ព្រមទាំងតតិយជន ឬអាចជាជនអនាមិកដែលបានរាយការណ៍ជូនមកមន្ត្រីនគរបាលយុត្តិធម៌ផ្ទាល់។ បេសកម្មទាំងនេះមានពីរប្រភេទគឺ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម។ ការស៊ើបអង្កេតនីមួយៗមន្ត្រីនគរបាលយុត្តិធម៌ត្រូវ តែត្រួតពិនិត្យឱ្យបានច្បាស់លាស់នូវនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ប្រសិន បើការស៊ើបអង្កេតណាមួយមិនស្រប ទៅនឹងនីតិវិធីដែលមានចែងនៅក្នុងច្បាប់ទេ ពេលនោះការស៊ើបអង្កេតនឹងត្រូវចាត់ទុកជាមោឃៈ។

# អនុសាសន៍

# អនុសាសន៍

ជាទីបញ្ចប់តាមការស្រាវជ្រាវរបស់យើងខ្ញុំ ដើម្បីចូលរួមចំណែកសារណារបស់យើងខ្ញុំមួយនេះ ដូច្នេះយើងខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនដូចខាង អាចយកទៅអនុវត្តបាននៅក្នុងប្រទេសជាតិក្រោម ៖

- សូមសំណូមពរទៅដល់ប្រជាពលរដ្ឋគ្រប់រូប សូមមេត្តាជួយសហការណ៍គ្នា ជាមួយមន្ត្រីនគរបាលយុត្តិធម៌ពេលមានបទល្មើសកើតឡើង។ ក្នុងការសហការណ៍ជាមួយមន្ត្រីនគរបាលយុត្តិធម៌មានដូចជាត្រូវតែរាយការណ៍ទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលមានទីតាំងនៅជិតកន្លែងកើតហេតុបំផុត។ ប្រជាពលរដ្ឋគ្រប់រូបអាចដាក់ពាក្យបណ្តឹងដោយចំហរ ឬពាក្យបណ្តឹងអនាមិកក៏បានដែរ ដោយមិនគិត ថាប្រជាពលរដ្ឋរូបនោះជាជនរងគ្រោះផ្ទាល់ ឬតតិយជនក្តី គឺមានសិទ្ធិដាក់ពាក្យបណ្តឹងបាន។
- សូមសំណូមពរដល់មន្ត្រីនគរបាលយុត្តិធម៌ យកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋ ជាពិសេសលើកស្ទួយដល់វិស័យយុត្តិធម៌ និងការអនុវត្តន៍ច្បាប់។ ហើយសំណូមពរដល់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ឱ្យលុបបំបាត់ចោល នូវអំពើពុករលួយ ជាពិសេស អ្នកធ្វើកំណត់ហេតុ និងអ្នកធ្វើកោសលវិច្ច័យ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅដោយយុត្តិធម៌យ៉ាងល្អបំផុត ជាងនេះទៅទៀត បានធ្វើឱ្យប្រទេសជាតិមានភាពតម្លាភាព និងនីតិរដ្ឋ។
- សូមឱ្យមានការរីកចំរើននៃវិស័យច្បាប់ ទាក់ទងនិងផ្នែកព្រហ្មទណ្ឌ នៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះដំណាក់កាលនេះគឺពឹងផ្អែកទាំងស្រុងទៅលើសមត្ថភាព និងបច្ចេកទេស ឬជំនាញមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបង្ការ និងបង្ក្រាបបទល្មើសដែលកើតមានឡើង។
- សូមឱ្យមន្ត្រីនគរបាលយុត្តិធម៌ រក្សាសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារប្រទេសជាតិ កុំឱ្យមានភាពវឹកវរ ដើម្បីជៀសវាងកុំឱ្យមានភាពអសកម្មនៅក្នុងសង្គមជាតិ។
- មន្ត្រីនគរបាលយុត្តិធម៌ទាំងឡាយ សូមគោរពតាមតួនាទី និងតាមច្បាប់ឱ្យបាននូវក្រមសីលធម៌ជាមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងគោរពតាមគោលណ៏របស់ច្បាប់ដែលបានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បើមិនគោរពតាមច្បាប់នោះទេ និងធ្វើឱ្យមានការរំលោភបំពាននូវ សិទ្ធិមនុស្ស សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋគ្រប់រូប ដែលធ្វើឱ្យប្រទេសជាតិបាត់បង់នូវនីតិរដ្ឋ និងសន្តិភាពទាំងស្រុង។

# ឯកសារយោង

# ឯកសារយោង

## ១. រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

## ២. ឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត

### ២.១. ច្បាប់

- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
- ច្បាប់ស្តីពីការបរឆាំងអំពើពុករលួយ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត-ក្រុង-ខណ្ឌ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨។
- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។
- ច្បាប់ស្តីពីជលផល ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។
- ច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២។

### ២.២. ប្រកាស

- ប្រកាសស្តីពីរបៀបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ របស់ក្រសួងយុត្តិធម៌ លេខ ២៧ ប្រ.ក រ.ប.ក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤។
- ប្រកាសរួមស្តីពីការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ រវាងក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គណៈកម្មការមូលបត្រកម្ពុជា) លេង៤៤ ប្រ.ក.ក.យ.គ.ម.ក/១០ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០។
- ប្រកាសអន្តក្រសួងស្តីពី ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ រវាងក្រសួងយុត្តិធម៌ និងក្រសួងទេសចរណ៍ លេខ ៥៦ ប្រ.ក.ក.យ.ក.ទ.ច/១០ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។
- ប្រកាសអន្តក្រសួងស្តីពី ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ រវាងក្រសួងយុត្តិធម៌ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ៥៦ ប្រ.ក.ក.យ.ក.ស.ស/០៨ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០០៨។

## ៣. សៀវភៅគោលនិពន្ធ និងឯកសារផ្សេងទៀត

- សៀវភៅ នគរបាលយុត្តិធម៌ និពន្ធដោយលោកអនុបណ្ឌិត កៅ សីហា បោះពុម្ពផ្សាយនៅឆ្នាំ២០១២។
- សទ្ទានុក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តធម៌។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្ម មាត្រា១៤៥ និង មាត្រា១៤៦ ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី២៖ ច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា១៤១

ឧបសម្ព័ន្ធទី៣៖ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ឧបសម្ព័ន្ធទី៤៖ ក្រមសីលធម៌សំរាប់មន្ត្រីនគរបាលប្រតិបត្តិ

ឧបសម្ព័ន្ធទី៥៖ ប្រកាសអង្គរក្រសួង ស្ដីពី កាផ្ដល់ននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

ឧបសម្ព័ន្ធទី៦៖ គម្រូស្ដីពីសម្បថ

ឧបសម្ព័ន្ធទី៧៖ គម្រូសញ្ញាបត្រ និង វិញ្ញាបនបត្រ

# ឧបសម្ព័ន្ធទី១

# ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម

# មាត្រា១៤៥ និង មាត្រា១៤ថ្មី

# រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

នស/រកម/០២០៨/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្ក
  ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩
  ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមក
  ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជ
  ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១៤៥ ថ្មី និងមាត្រា ១៤៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភ ពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ ក្នុងមាត្រ ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ

# ច្បាប់ធម្មនុញ្ញ

## ស្តីពីវិសោធនកម្ម

## មាត្រា១៤៥ថ្មី និងមាត្រា១៤៦ ថ្មី

## នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រាមួយ.–

មាត្រា ១៤៥ ថ្មី និងមាត្រា ១៤៦ ថ្មី ជំពូកទី ១៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

មាត្រា១៤៥ .–ថ្មី (មួយ)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក-ខណ្ឌ ឃុំ សង្កាត់ ។

មាត្រា១៤៦ .–ថ្មី (មួយ)

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ។

មាត្រាពីរ .–

ច្បាប់ធម្មនុញ្ញនេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៨

នស/រកម.០៤០២.១៣៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ ១៣៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០០៨

[illegible]រាជរដ្ឋាភិបាល

# ឧបសម្ព័ន្ធទី២
# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល
# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

**មាត្រា ១៣៩.-**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.-**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

# ឧបសម្ព័ន្ធទី៣

# ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមនីតិវិធីព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា



ឆ្នាំ ២០០៧

ក្រសួងយុត្តិធម៌

Ministère de la Justice

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

34/2007

## គន្ថីទី ២
## អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ស៊ើបសួរ និងស៊ើបអង្កេត
## មាតិកាទី ១
## អង្គការអយ្យការ
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៧.** – តួនាទីរបស់អង្គការអយ្យការ

អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងជានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ។

ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ ។

**មាត្រា ២៨.** – ចៅក្រមអយ្យការ

ចៅក្រមអយ្យការមាន :

១-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។

២-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣-ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។

**មាត្រា ២៩.** – ឋានានុក្រមនៃអង្គការអយ្យការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់ទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យ

នៅក្នុងសាលាឧទ្ធរណ៍មានសភាមួយដែលមានឈ្មោះថា សភាស៊ើបសួរ ។ សភាស៊ើបសួរមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ។

សមាជិកនៃសភាស៊ើបសួរពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើមិនដូច្នេះទេ សាលដីកានោះត្រូវចាត់ទុកជាមោឃៈ ។

## មាតិកាទី ៤
## នគរបាលយុត្តិធម៌
### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៦.** – បេសកកម្មរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ ។

នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង ។

**មាត្រា ៥៧.** – សមាសភាពរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌រួមមាន :

១-មន្ត្រីនគរបាលយុត្តិធម៌

២-ភ្នាក់ងារនគរបាលយុត្តិធម៌

៣-មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៥៨.** – ការសម្របសម្រួលសកម្មភាពការងាររបស់នគរបាលយុត្តិធម៌

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។

ព្រះរាជអាជ្ញាមានអំណាចទៅលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលចែងនៅក្នុងមាត្រា ៨២ (ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត) នៃក្រមនេះ កាលណាមន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌ ។

កាលណាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ។

**មាត្រា ៥៩.** – ការត្រួតពិនិត្យលើនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ ។

## ជំពូកទី ២
## មន្ត្រីនគរបាលយុត្តិធម៌
### ផ្នែកទី ១
### ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៦០.** – មន្ត្រីនគរបាលយុត្តិធម៌

មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ :

១-មន្ត្រីនគរបាលជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំពេញការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំ ក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។

២-នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបំពេញការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។

៣-អ្នកមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម :

ក. អភិបាល និងអភិបាលរង ខេត្ត ក្រុង, អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ។

ខ. ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌនិងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

ឃ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក នៃ :

- នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"

- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភ័ណ្ឌ ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង ។

ច. ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា :

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម និង
- ការិយាល័យជនបរទេស ។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ ។

ជ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ" ។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធ ជាតិផ្ទុះ" ។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធាន ផ្នែកនៃការិយាល័យនគរបាលទេសចរណ៍ ។

ឈ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ" ។

ញ. មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ដ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឋ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឈ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់ ។

រដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាល ឬជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចទី១ ទី២ និងទី៣ នៃមាត្រានេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៦១.** – សញ្ញាប័ត្រជាន់ខ្ពស់របស់នគរបាលយុត្តិធម៌

សញ្ញាប័ត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ ត្រូវផ្តល់ជូនបន្ទាប់ពីឆ្លងកាត់ការប្រលងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋានដូចខាងក្រោម :

១-វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ ។

២-វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

៣-វិញ្ញាសាស្តីពីករណីយកិច្ចសាស្ត្រ ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ដែលគាក់តែងដោយអង្គការសហប្រជាជាតិ ។

សញ្ញាប័ត្រនេះត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធ និងមានបោះត្រាផង ។

**មាត្រា ៦២.** – គណៈមេប្រយោគ

គណៈមេប្រយោគនៃការប្រលង ស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ ។

១-ទាក់ទងនឹងមន្ត្រីនៃនគរបាលជាតិ គណៈមេប្រយោគមានសមាសភាពដូចតទៅ :

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប របស់ក្រសួងមហាផ្ទៃ ។

២-ទាក់ទងនឹងយោធិននៃកងរាជអាវុធហត្ថ គណៈមេប្រយោគមានសមាសភាពដូចតទៅ :

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប មកពីក្រសួងការពារជាតិ ។

បែបបទនៃការចេញសញ្ញាប័ត្រ ត្រូវកំណត់ដោយប្រកាសរួមមួយ រវាងរដ្ឋមន្ត្រីពាក់ព័ន្ធ ។

**មាត្រា ៦៣.** – សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវស្បថថា ខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាររបស់ខ្លួន ។ សម្បថត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍ ។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត ។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ផ្នែកទី ២
## កំហុសប្រព្រឹត្តក្នុងពេលអនុវត្តមុខងារ

**មាត្រា ៦៤.** – នីតិវិធីខាងវិន័យ

រាល់កំហុសទាំងឡាយ ដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តមុខងាររបស់ខ្លួន ត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីផ្តើមដំណើរការនីតិវិធីវិន័យ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការជាបន្តនៃនីតិវិធីវិន័យនេះ ។

**មាត្រា ៦៥.** – ទណ្ឌកម្មខាងវិន័យ

ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

កាលណាមន្ត្រីនគរបាលយុត្តិធម៌ ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន យុត្តាធិការស៊ើបសួរ ឬជំនុំជម្រះដែលទទួលបន្ទុករឿងនេះ ត្រូវផ្ទេរសំណុំរឿងតាមសេចក្តីសម្រេចរបស់តុលាការកំពូលទៅឱ្យយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី ។

ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ។

**មាត្រា ៦៦.** – ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា សភាពធ្ងន់ធ្ងរនៃកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មានវិសមិតភាពជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោម :

១-ហាមឃាត់មិនឱ្យបំពេញមុខងារ ជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្ន

សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត ។

២-ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ ។

មុននឹងចេញសេចក្ដីសម្រេចរបស់ខ្លួន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ កោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកនូវសេចក្ដីសង្កេតរបស់មន្ត្រីនោះ ។ សាមីជនអាចរកជំនួយពីមេធាវី ឬពីទីប្រឹក្សាម្នាក់ តាមការជ្រើសរើសរបស់ខ្លួន ។

សេចក្ដីសម្រេចពីការហាមឃាត់ ត្រូវតែបញ្ជាក់សំអាងហេតុ ។ សេចក្ដីសម្រេចនេះ ត្រូវផ្ដល់ជាដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៅតាមករណីនីមួយៗ ។

សេចក្ដីសម្រេចនេះ អាចជាកម្មវត្ថុនៃបណ្ដឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលអាចប្រកាសបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់របស់អគ្គព្រះរាជអាជ្ញា ។ ក្រសួងសាមីនៃមន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ អាចបញ្ជូនយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់ អាចដាក់ពាក្យប្ដឹងតវ៉ាដោយមានសំអាងហេតុ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចហាមឃាត់នោះ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចសេចក្ដីលើបណ្ដឹងតវ៉ាខាងលើ ក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យប្ដឹង ។ សេចក្ដីសម្រេចនេះ មិនអាចប្ដឹងតវ៉ាបានឡើយ ។

ក្នុងអំឡុងពេលដែលអាចធ្វើបណ្ដឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្ដីលើបណ្ដឹងតវ៉ា មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ឡើយ ។ មន្ត្រីនេះអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌វិញបាន ប្រសិនបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់ ។

កិច្ចទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌បានបំពេញ ដោយបំពានសេចក្ដីសម្រេចពីការហាមឃាត់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នេះ ត្រូវចាត់ទុកជាមោឃៈ ។

## ផ្នែកទី ៣
## សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៦៧.** – មណ្ឌលរដ្ឋបាលបំពេញការងារ

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួន

ត្រូវបានចាត់តាំងឱ្យទៅបំពេញការងារ ។

នៅភ្នំពេញមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃក្រុងទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្ទាល់ទៅកាន់នោះ នៅកន្លែងណាក៏ដោយ ។

សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់មណ្ឌលរដ្ឋបាល ដែលមន្ត្រីនោះត្រូវចាត់តាំងឱ្យទៅបំពេញការ ។ សេចក្តីសម្រេចនេះ ត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

**មាត្រា ៦៨.** – ការពន្យាតសមត្ថកិច្ចដែនដី

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៧ (ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ ហើយប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល ។ ការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់ ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត ។

ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ក្នុងករណីបន្ទាន់ ចៅក្រមនេះ អាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីជាតិទាំងមូល ។

កាលណាធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី ។

ចៅក្រមដែលបានអនុញ្ញាតឱ្យមានការពន្យាតសមត្ថកិច្ច ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ។

**មាត្រា ៦៩.** – កម្មវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច

វិធាននៃសមត្ថកិច្ចខាងដែនដីដែលបានបញ្ញត្តនៅក្នុងមាត្រាមុនៗនេះ មានលក្ខណៈដាច់ខាត ។ បើមិនគោរពតាមទេនោះ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ ។

**មាត្រា ៧០.** – សេចក្តីបង្គាប់បញ្ជារបស់អាជ្ញាធរតុលាការ

មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ទទួលបញ្ជា ឬសុំបញ្ជាតែពីអាជ្ញាធរតុលាការ ។

## ផ្នែកទី ៤
## បេសកកម្មនៃមន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៧១.** – កំណត់ហេតុនៃបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌ទទួលបណ្ដឹងទាមទារ និងបណ្ដឹងបរិហារ ។ មន្ត្រីនគរបាលយុត្តិធម៌ពិនិត្យបទល្មើសទាំងឡាយ ។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្ដែង និងធ្វើការស៊ើបអង្កេតបឋម ក្នុងលក្ខខណ្ឌនៃមាត្រា ៨៤ (ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត) ដល់មាត្រា ១១០ (អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម) នៃក្រមនេះ ។

កាលណាការស៊ើបសួរបានចាប់ផ្ដើម មន្ត្រីនគរបាលយុត្តិធម៌ អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរនៅក្នុងលក្ខខណ្ឌដែលបានចែងដោយមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

**មាត្រា ៧២.** – កំណត់ហេតុ

គ្រប់បណ្ដឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌នោះ តម្រូវឱ្យមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវស្រង់ដោយត្រឹមត្រូវនូវសេចក្ដីរាយការណ៍របស់អ្នកប្ដឹង ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅអ្នកបកប្រែភាសាម្នាក់ដែលត្រូវស្បថតាមជំនឿ ឬសាសនាថា ខ្លួននឹងបកប្រែភាសាឱ្យបានត្រឹមត្រូវតាមសេចក្ដីរាយការណ៍ ។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការបានឡើយ ។

កំណត់ហេតុស្ដីអំពីការដាក់ពាក្យប្ដឹងត្រូវមានចុះសេចក្ដីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នេះ

-កាលបរិច្ឆេទ ។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្ដឹង ។

ការឆូត ការថែម និងការយោង ត្រូវតែមានបញ្ជាក់ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្ដឹង នៅរឹមទំព័រ ។

មុននឹងចុះហត្ថលេខា ឬផ្ដិតម្រាមដៃ អ្នកប្ដឹងត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានខ្លឹមសារកំណត់ហេតុដោយសំលេងខ្លាំងៗ ។

**មាត្រា ៧៣.** – បញ្ជីបណ្តឹង

នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវតែមានបញ្ជីបណ្តឹងមួយ ។ នៅគ្រប់ពេលដែលមានការដាក់ពាក្យប្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងបញ្ជីនូវនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណរបស់អ្នកប្តឹង

-កាលបរិច្ឆេទនៃការដាក់ពាក្យប្តឹង

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹង

-ប្រភេទនៃអំពើដែលប្តឹង

-ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ផ្តើមធ្វើការស៊ើបអង្កេត ។

បញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

**មាត្រា ៧៤.** – ចំណាត់ការបន្តពីការដាក់ពាក្យប្តឹង

មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងនោះ ត្រូវតែចាប់ផ្តើមភ្លាមៗ ធ្វើការស៊ើបអង្កេត ឬក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនោះ ទៅព្រះរាជអាជ្ញាដើម្បីចាត់ការតទៅ ។

មន្ត្រីនគរបាលយុត្តិធម៌ មុនធ្វើការស៊ើបអង្កេត អាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា ។

កាលណាទទួលពាក្យប្តឹងបរិហារ ដែលមានបង្ហាញមូលហេតុជាក់ច្បាស់សមហេតុផល មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ ។

**មាត្រា ៧៥.** – ការបំពានលើសកម្មភាពតុលាការ

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬក៏មានការដកពាក្យប្តឹងក៏ដោយ ។

មន្ត្រីនគរបាលយុត្តិធម៌ដែលរក្សាទុកកំណត់ហេតុ ឬវត្ថុតាងដោយចេតនា ឬក៏លាក់បំបាំងដល់អាជ្ញាធរតុលាការអំពីអត្ថិភាពនៃកំណត់ហេតុ ឬវត្ថុតាង ត្រូវចាត់ទុកថាមន្ត្រីនគរបាលនោះបានប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងជំពូកស្តីពីការស្រាវជ្រាវរកភស្តុតាង ។

## ជំពូកទី ៣
## ភ្នាក់ងារនគរបាលយុត្តិធម៌

**មាត្រា ៧៦.** – ការទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌

មានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ :

១-នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

២-ភ្នាក់ងារនគរបាលជាតិផ្សេងទៀត ។

៣-នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

៤-យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ ។

**មាត្រា ៧៧.** - សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ។ សម្បថនេះត្រូវធ្វើឡើងនៅចំពោះមុខសាលាដំបូង ។ សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ នាពេលក្រោយទៀត ។ រូបមន្តសម្បថ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧៨.** - បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ មានបេសកកម្ម :

១-ពិនិត្យបទល្មើស ជាអាទិ៍ បទលហុ ។

២-ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់គេ ។

ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍ ។ របាយការណ៍នេះ មានតំលៃត្រឹមតែព័ត៌មានធម្មតា ។

ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយ ដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌ ។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះ ត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា ៧៩.** - កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ

រាល់កំហុសទាំងឡាយ ដែលប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។

**មាត្រា ៨០.** – ទណ្ឌកម្មខាងវិន័យ

ទណ្ឌកម្មខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

កាលណាភ្នាក់ងារនគរបាលយុត្តិធម៌ ប្រព្រឹត្តបទល្មើសនៅក្នុងការបំពេញមុខងាររបស់ខ្លួន តុលាការកំពូលអាចផ្ទេរអំណាចឱ្យទៅយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ ។

ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ។

## ជំពូកទី ៤
## ការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធហត្ថ

**មាត្រា ៨១.** – ការកំណត់សមត្ថកិច្ច

ក្នុងវិស័យនគរបាលយុត្តិធម៌ នគរបាលជាតិ និងកងរាជអាវុធហត្ថ ត្រូវមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៥៦ (បេសកកម្មរបស់នគរបាលយុត្តិធម៌) នៃក្រមនេះ ។

លើសពីនេះទៅទៀត ចំពោះបទល្មើសយោធា មានតែកងរាជអាវុធហត្ថទេ ដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌ ។

កិច្ចប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងនាយនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ ក្នុងពេលបំពេញមុខងារជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

អង្គភាពនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចថ្នាក់ជាតិ អាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៥
## មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន

**មាត្រា ៨២.** – ការផ្ដល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យពិនិត្យបទល្មើស ត្រូវដាក់ឱ្យស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ ។ បែបបទ និងនីតិវិធីនៃការផ្ដល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ ។

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយ

ស្មោះត្រង់ ។ សម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូង ។ រូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។

ចំពោះការពិនិត្យបទល្មើស មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះ ធ្វើរបាយការណ៍ ។ របាយការណ៍នេះ មានតំលៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ ។

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬភ្នាក់ងារនោះនៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។ ទណ្ឌកម្មខាងវិន័យ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត ។

# ឧបសម្ព័ន្ធទី៤

# ក្រមសីលធម៌សំរាប់មន្ត្រីនគរបាលប្រតិបត្តិ

# ក្រមសីលធម៌សំរាប់

# មន្ត្រីប្រតិបត្តិច្បាប់

# Code of Conduct
# for Law Enforcement Officials



# ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់

# Code of Conduct for Law Enforcement Officials

*អនុម័តដោយសេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៣៤/១៦៩ ចុះថ្ងៃ ទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ ។*

*Adopted by General Assembly resolution 34/169 of 17 December 1979.*

## មាត្រា ១

ក្នុងការបំរើសហគមន៍ និងក្នុងការការពារមនុស្សគ្រប់រូបកុំឱ្យប្រព្រឹត្តខុសច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់គ្រប់ពេលវេលា ដោយមានការទទួលខុសត្រូវខ្ពស់តាមវិជ្ជាជីវៈរបស់ខ្លួន ។

***អត្ថាធិប្បាយ :***

ក- ពាក្យថា " មន្ត្រីប្រតិបត្តិច្បាប់ " សំដៅដល់មន្ត្រីទាំងអស់ ទោះជាត្រូវតែងតាំង ឬត្រូវជ្រើសតាំងក្តី ឱ្យតែប្រើប្រាស់អំណាចនគរបាល ជាពិសេសអំណាចក្នុងការចាប់ខ្លួន ឬឃុំខ្លួន ។

ខ- នៅក្នុងប្រទេសទាំងឡាយ ដែលអាជ្ញាធរយោធាប្រើប្រាស់អំណាចនគរបាល ទោះជាមាន ឬគ្មានឯកសណ្ឋានក្តី ឬដោយកំលាំងសន្តិសុខរបស់រដ្ឋ មន្ត្រីទាំងឡាយដែលបំរើការងារនោះត្រូវចាត់ចូលក្នុងនិយមន័យនៃមន្ត្រីប្រតិបត្តិច្បាប់ ។

គ- ការផ្តល់សេវាបំរើសហគមន៍ គឺមានគោលដៅដាក់បញ្ចូលជាពិសេសនូវសេវាជំនួយឧបត្ថម្ភដល់សមាជិកសហគមន៍ទាំងនោះ ហើយដោយសារតែមូលហេតុផ្ទាល់ខ្លួន មូលហេតុសេដ្ឋកិច្ច មូលហេតុសង្គមកិច្ច ឬភាពបន្ទាន់បង្ខំផ្សេងទៀត ទើបពួកគេត្រូវការជំនួយទាំងនេះជាបន្ទាន់ ។

ឃ- បញ្ញត្តិនេះមានគោលដៅធ្វើការទប់ស្កាត់ មិនត្រឹមតែអំពើហិង្សា អំពើសាហាវព្រៃផ្សៃ និងការធ្វើទុក្ខទោសដល់អ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងធ្វើការទប់ស្កាត់ចំពោះអំពើល្មើសផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ បញ្ញត្តិនេះក៏ អនុវត្តចំពោះជនទាំងឡាយដែលមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទ័ណ្ឌផងដែរ ។

## មាត្រា ២

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ រក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់ជនគ្រប់រូប ។

***អត្ថាធិប្បាយ :***

ក- សិទ្ធិមនុស្សដូចមានចែងខាងលើ ត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ក្នុងនោះមានលិខិតុបករណ៍ពាក់ព័ន្ធមួយចំនួន ដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីប្រកាសស្តីពីការពារជនគ្រប់រូប កុំឱ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់ នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបង្រ្កាប និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃពួកអាប៉ាថេដ អនុសញ្ញាអន្តរជាតិស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បញ្ញត្តិជាបទដ្ឋានអប្បបរមា សំរាប់គ្រប់គ្រងអ្នកទោស ហើយនិងមាន អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ។

ខ- សេចក្តីអត្ថាធិប្បាយថ្នាក់ជាតិលើបញ្ញត្តិនេះ គួរបញ្ជាក់ថាជាបទបញ្ញត្តិថ្នាក់ជាតិ ឬថ្នាក់តំបន់ដែលបានទទួលស្គាល់ និងការពារសិទ្ធិទាំងនេះ ។

## មាត្រា ៣

មន្ត្រីប្រតិបត្តិច្បាប់អាចប្រើប្រាស់កំលាំងបាន តែក្នុងកាលៈទេសៈណាដែលចាំបាច់បំផុត និងស្ថិតនៅក្នុងវង្ស់នៃការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

***អត្ថាធិប្បាយ :***

ក- បញ្ញត្តិនេះបញ្ជាក់ថា ការប្រើប្រាស់កំលាំងដោយមន្ត្រីប្រតិបត្តិច្បាប់អាចមានការលើកលែង មានន័យថា មន្ត្រីប្រតិបត្តិច្បាប់ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់កំលាំងតាមការចាំបាច់ និងសមហេតុផល ដើម្បីទប់ស្កាត់បទល្មើស ឬដើម្បីធ្វើឱ្យមានប្រសិទ្ធិភាព ឬដើម្បីជួយក្នុងការចាប់ខ្លួនជនល្មើស ឬជនសង្ស័យតាមច្បាប់ ប៉ុន្តែមិនត្រូវប្រើកំលាំងហួសហេតុឡើយ ។

ខ- តាមធម្មតា ច្បាប់ជាតិនៃប្រទេសនីមួយៗ បានដាក់កំហិតយ៉ាងតឹងតែងដល់មន្ត្រីប្រតិបត្តិច្បាប់ក្នុងការប្រើប្រាស់កំលាំងនេះ ដោយអនុលោមតាមគោលការណ៍សមាមាត្រ ។ គេក៏ត្រូវយល់ដែរថា គេត្រូវគោរពតាមគោលការណ៍ជាតិស្តីពីសមាមាត្រក្នុងការបកស្រាយបញ្ញត្តិនេះ ។ ទោះជាក្នុងករណីណាក៏ដោយ មិនត្រូវធ្វើការបកស្រាយ

បញ្ញត្តិនេះ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់កំលាំង ដែលមិនសមាមាត្រ ដើម្បីសំរេចបាននូវគោលដៅស្របច្បាប់ណាមួយឡើយ ។

គ- ការប្រើប្រាស់អាវុធត្រូវបានគេចាត់ទុកថា ជាវិធានការមួយដែលខ្លាំងក្លាបំផុត ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវខំជៀសវាងការប្រើប្រាស់អាវុធ ជាពិសេសទៅលើអនីតិជន ។ ជាទូទៅ ការប្រើអាវុធត្រូវហាមឃាត់ លើកលែងតែក្នុងករណីណាដែលជនល្មើសតដៃ ឬបង្កគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ ឬក្នុងកាលៈទេសៈណាដែលការចាត់វិធានការមិនមានកំលាំងគ្រប់គ្រាន់ ដើម្បីបញ្ឈប់ ឬចាប់ខ្លួនជនល្មើស ។ ពេលណាដែលមានការបាញ់កាំភ្លើងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចភ្លាម ។

## មាត្រា ៤

ចំពោះរឿងរ៉ាវទាំងឡាយមានចរិតជាការសំងាត់ ហើយដែលឋិតនៅក្នុងដៃមន្ត្រីប្រតិបត្តិច្បាប់ត្រូវតែរក្សាទុកជាសំងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬត្រូវស្វែងរកយុត្តិធម៌ ។

***អត្ថាធិប្បាយ :***

តាមប្រភេទការងាររបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ ទទួលពត៌មាននានា ដែលអាចមានការទាក់ទងដល់ជីវិតរស់នៅផ្ទាល់ខ្លួន ឬដែលអាចបណ្តាលឱ្យខូចខាតដល់ប្រយោជន៍ជាសក្តានុពល ឬជាពិសេសប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវប្រុងប្រយ័ត្នបំផុតក្នុងការរក្សា និងការប្រើប្រាស់ពត៌មាននេះ ហើយព័ត៌មាននេះអាចលាតត្រដាងបានសំរាប់តែការបំពេញភារកិច្ច ស្វែងរកយុត្តិធម៌តែប៉ុណ្ណោះ ។ ការយករឿងអាថ៌កំបាំងរបស់អ្នកដទៃ ទៅលាតត្រដាងក្នុងគោលបំណងអ្វីផ្សេងពីនេះ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះនេះជាការមិនសមរម្យទាល់តែសោះ ។

## មាត្រា ៥

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនអាចប្រព្រឹត្ត ធ្វើការញុះញង់ ឬបណ្តោយឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតឡើយ ។ ក្រៅពីនេះ មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវដាក់បញ្ជាបែបជាចៅហ្វាយនាយផ្សេងៗ ឬមានការលើកលែងចំពោះករណីមួយចំនួនដូចជា ក្នុងស្ថានភាពដែលមានសង្គ្រាម ឬការគំរាម

## មាត្រា ៦

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបត្រូវធានារក្សាសុខភាពជនទាំងឡាយដែលឋិតក្នុងការឃុំឃាំងរបស់ខ្លួនឱ្យបានពេញលេញបរិបូរណ៍ ជាពិសេស ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាឱ្យមានការព្យាបាលជម្ងឺ តាមការចាំបាច់ ។

***អត្ថាធិប្បាយ :***

ក- "ការព្យាបាលជម្ងឺ" សំដៅដល់ការផ្តល់សេវាផ្សេងៗដោយបុគ្គលិកផ្នែកសុខាភិបាល ក្នុងនោះមានគ្រូពេទ្យជំនាញវិជ្ជាជីវៈ និងគ្រូពេទ្យជំនួយ ដែលគ្រូពេទ្យទាំងនេះត្រូវធានាឱ្យមានជានិច្ចសំរាប់បំរើសេចក្តីត្រូវការ ។

ខ- ប្រសិនបើបុគ្គលិកផ្នែកសុខាភិបាលចាំបាច់ត្រូវចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយមន្ត្រីប្រតិបត្តិច្បាប់ ហើយមន្ត្រីប្រតិបត្តិច្បាប់ត្រូវពិចារណាលើការវិនិច្ឆ័យរបស់បុគ្គលផ្នែកសុខាភិបាលទាំងនេះ នៅពេលដែលគេព្យាបាលជនដែលនៅក្នុងការឃុំគ្រងរបស់ខ្លួន តាមរយៈ ឬក្នុងការពិគ្រោះយោបល់ជាមួយបុគ្គលិកផ្នែកសុខាភិបាលដែលមិនឋិតក្នុងកិច្ចប្រតិបត្តិការរបស់មន្ត្រីប្រតិបត្តិច្បាប់ ។

គ- មន្ត្រីប្រតិបត្តិច្បាប់ក៏ត្រូវធានាឱ្យមានការព្យាបាលសុខភាពដល់ជនរងគ្រោះ ដោយការរំលោភច្បាប់ ឬដោយឧបទ្ទវហេតុផ្សេងៗ ដែលកើតឡើងក្នុងពេលមានការប្រព្រឹត្តរំលោភច្បាប់ផងដែរ ។

## មាត្រា ៧

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះឱ្យបានយ៉ាងខ្លាំងក្លា ។

***អត្ថាធិប្បាយ :***

ក- អំពើពុករលួយ ក៏ដូចគ្នានឹងការបំពានច្បាប់របស់រដ្ឋពីសំណាក់អាជ្ញាធរដែរ ហើយអំពើបែបនេះជាអំពើដែលផ្ទុយពីកាតព្វកិច្ចរបស់មន្ត្រីប្រតិបត្តិច្បាប់ ។ មន្ត្រីប្រតិបត្តិច្បាប់ដែលប្រព្រឹត្តអំពើពុករលួយត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ ដោយគ្មានការយោគយល់ឡើយ ព្រោះថារដ្ឋាភិបាលពុំអាចយកច្បាប់ មកគ្រប់គ្រងលើប្រជាពលរដ្ឋបានទេ ប្រសិនបើ រដ្ឋាភិបាលមិនអាចអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវទៅលើភ្នាក់ងារ ឬស្ថាប័នរបស់ខ្លួន ។

ខ- និយមន័យនៃពាក្យ "អំពើពុករលួយ" ត្រូវតែមានចែងក្នុងច្បាប់ជាតិ ។ ការរួមគំនិតប្រព្រឹត្តអំពើសូកប៉ាន់ផ្សេងៗ គឺជាបទល្មើសពុករលួយ ។ នៅពេលកំពុងបំពេញភារកិច្ចក្នុងនាម ជាមន្ត្រីប្រតិបត្តិច្បាប់ បើមានការ

ព្រមើយកន្តើយមិនបង្រ្កាបអំពើស្ទុកចាំន់ឱ្យបានច្បាស់លាស់ទេ មន្ត្រីប្រតិបត្តិច្បាប់ ត្រូវចាត់ទុកថា បានឃុបឃិតក្នុងអំពើពុករលួយដែរ ។ ការទទួលអំណោយ (ជាវត្ថុ ឬជាប្រាក់) រង្វាន់លើកទឹកចិត្តផ្សេងៗ ការសន្យានានា ដែលមិនសមស្របទៅនឹងវិន័យត្រូវចាត់ទុកថាជាបទល្មើសពុករលួយ ។

គ- ពាក្យថា "អំពើពុករលួយ" ដែលបានចែងក្នុងប្រយោគខាងលើ ត្រូវរាប់បញ្ចូលផងដែរនូវឥទ្ធិៈ ឬការប៉ុនប៉ងទទួលសំណូកគ្រប់ប្រភេទ ។

## មាត្រា ៨

មន្ត្រីប្រតិបត្តិច្បាប់គ្រប់ស្រទាប់ជាន់ថ្នាក់ ត្រូវគោរពតាមច្បាប់ និងបទវិន័យនេះ ហើយត្រូវទប់ស្កាត់ និងប្រឆាំងយ៉ាងខ្លាំងក្លាបំផុតចំពោះអំពើទាំងឡាយណា ដែលបំពាន ឬប៉ះពាល់ដល់ច្បាប់ និងបទវិន័យនេះ ។

មន្ត្រីប្រតិបត្តិច្បាប់ ដែលដឹងប្រាកដថា មានជនណាម្នាក់បានរំលោភ ឬប្រុងនឹងរំលោភលើបទវិន័យនេះ ត្រូវតែរាយការណ៍អំពីរឿងនេះទៅអាជ្ញាធរថ្នាក់លើ ហើយប្រសិនជាចាំបាច់ត្រូវរាយការណ៍ទៅស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ ។

***អត្ថាធិប្បាយ :***

ក- គេត្រូវតែគោរពតាមបទវិន័យនេះភ្លាម កាលណាបទវិន័យនេះបានត្រូវគេបញ្ចូលទៅក្នុងក្របខ័ណ្ឌច្បាប់នីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។ ប៉ុន្តែនៅប្រទេសខ្លះច្បាប់នីតិបញ្ញត្តិ ឬនីតិប្រតិបត្តិរបស់គេ មានលក្ខណៈតឹងរឹងជាងបទវិន័យបច្ចុប្បន្ននេះទៅទៀត ។ ក្នុងករណីបែបនេះ មន្ត្រីប្រតិបត្តិច្បាប់ត្រូវតែគោរពតាមច្បាប់ដែលតឹងរឹងនោះ ។

ខ- មាត្រានេះ សំដៅធ្វើការថ្លឹងថ្លែងរវាងសេចក្តីត្រូវការឱ្យមានការគោលសំខាន់ពីរ គោលសំខាន់ទី១ គឺការរក្សា និងការពង្រឹងវិន័យផ្ទៃក្នុងរបស់ស្ថាប័ន ដើម្បីជាប្រយោជន៍ដ៏ទូលំទូលាយដល់សន្តិសុខសាធារណៈ ។ គោលសំខាន់ទី២ គឺការបង្ការ និងការការពារកុំឱ្យមានអំពើរំលោភលើសិទ្ធិមនុស្សជាមូលដ្ឋាន ។ បើមានការរំលោភច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវធ្វើសេចក្តីរាយការណ៍ជូនទៅនាយចៅហ្វាយតាមលំដាប់ឋានានុក្រម ។ ដរាបណាស្ថាប័នរបស់ខ្លួនបានប្រើគ្រប់មធ្យោបាយហើយនៅតែគ្មានប្រសិទ្ធិភាព ដរាបនោះមន្ត្រីប្រតិបត្តិច្បាប់ អាចរាយការណ៍អំពីរឿងរំលោភច្បាប់នេះ ទៅស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។ ក្នុងការធ្វើសេចក្តីរាយការណ៍អំពីការរំលោភលើបទវិន័យ ឬអំពីគំរោងផែនការ នៃការប្រព្រឹត្តអំពើពុករលួយណាមួយ អ្នករាយការណ៍ (មន្ត្រីប្រតិបត្តិច្បាប់) មិនត្រូវបាន ទទួលទណ្ឌកម្ម ឬជាកវិន័យរដ្ឋបាលណាមួយពីស្ថាប័នរបស់ខ្លួនឡើយ ។

ធ្វើសង្គ្រាម ការគំរាមដល់សន្តិសុខជាតិ អស្ថេរភាពនយោបាយផ្ទៃក្នុង ឬភាពចលាចលទូទៅណាមួយ ដែលជាមូលហេតុនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតនោះឡើយ ។

***អត្ថាធិប្បាយ :***

ក- ការហាមប្រាមនេះ មានចែងនៅក្នុងបញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីអំពីកិច្ចការពារបុគ្គលគ្រប់រូប ដើម្បីកុំឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយខ្លឹមសារនៃ [អំពើនេះ] គឺជាអំពើល្មើសមួយដែល ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើល្មើសនេះនឹងត្រូវផ្តន្ទាទោសដោយសារមិនព្រមអនុវត្តតាមស្មារតីធម្មនុញ្ញសហប្រជាជាតិ ហើយវាជាការរំលោភលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលមានចែងនៅក្នុងសេចក្តីប្រកាសជា សាកលស្តីពីសិទ្ធិមនុស្ស [និងលិខិតុបករណ៍អន្តរជាតិដទៃទៀតដែលទាក់ទងនិងសិទ្ធិមនុស្ស] ។

ខ- សេចក្តីប្រកាសនេះបានឱ្យនិយមន័យនៃពាក្យទារុណកម្ម ដូចខាងក្រោមនេះ :

"...ពាក្យទារុណកម្ម សំដៅដល់អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ខាងផ្លូវកាយ ឬផ្លូវចិត្ត ដែលមន្ត្រីសាធារណៈណាម្នាក់បង្កឡើងដោយចេតនា ឬដោយការញុះញង់របស់មន្ត្រីនោះ ឱ្យប្រព្រឹត្តលើជនណាម្នាក់ ក្នុងគោលបំណងឱ្យជននោះ ឬតតិយជនណាម្នាក់ ឱ្យផ្តល់ព័ត៌មាន ឬចំលើយសារភាព ការដាក់ទណ្ឌកម្មចំពោះអំពើ ដែលជននោះបានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬធ្វើការបំភិតបំភ័យជននោះ ឬជនដទៃផ្សេងទៀត ។ នេះមិនបានគិតពីការឈឺចាប់ ដែលកើតមានដោយសារការដាក់ទណ្ឌកម្មស្របច្បាប់ ក្នុងករិតមួយដែលស្របតាមបញ្ញត្តិ ដែលមានចែងក្នុង បទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស " ឡើយ ។

គ- ចំពោះពាក្យថា " ការប្រព្រឹត្ត ឬការធ្វើទណ្ឌកម្មឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប " មហាសន្និបាតមិនទាន់បានឱ្យអត្ថន័យពិស្តារនៅឡើយទេ ប៉ុន្តែពាក្យនេះគួរតែធ្វើការបកស្រាយយ៉ាងណា ដើម្បីពង្រីកការការពារឱ្យបានយ៉ាងទូលំទូលាយបំផុតតាមដែលអាចធ្វើបាន ប្រឆាំងរាល់ការរំលោភបំពានគ្រប់បែបយ៉ាង ខាងផ្លូវកាយ ឬ ផ្លូវចិត្ត ។

# ឧបសម្ព័ន្ធទី៥

# ប្រកាសអន្តរក្រសួង

# ស្តីពី

# ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាយុត្តិធម៌

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ៥៦ យុក.ភសរ កសក/០៨

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

Downloaded from http://www.khmerlaws.com

- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផលជលផល ទៅជារដ្ឋបាលជលផល
- បានឃើញប្រកាសលេខ ៣៨៦ ប្រក.កសក.ប ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃអង្គភាពរបស់រដ្ឋបាលជលផល
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១ :**

ត្រូវបានទទួលស្គាល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីរាជការដែលបំរើការងារនៅរដ្ឋបាលជលផល ដូចមានរាយនាមខាងក្រោម :

| ល.រ | គោត្តនាម_នាម | ភេទ | ឋានៈ និងតួនាទី | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ១ | ឯកឧត្តម ណៅ ធូក | ប្រុស | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុក ជាប្រធានរដ្ឋបាលជលផល | |
| ២ | ឯកឧត្តម ឡុង ឈាង | - | អនុប្រធានរដ្ឋបាលជលផល | |
| ៣ | លោក សម នៅ | - | អនុប្រធានរដ្ឋបាលជលផល | |
| ៤ | លោក អ៊ឹង ទ្រី | - | អនុប្រធានរដ្ឋបាលជលផល | |
| ៥ | លោក អេង ជាសាន | - | អនុប្រធានរដ្ឋបាលជលផល | |
| ៦ | លោក ពុំ សុថា | - | នាយ អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ៧ | លោក សុង ហុង | - | នាយ អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ | |
| ៨ | លោក ឡុង គន | - | នាយ អធិការដ្ឋានរដ្ឋបាលជលផលមេគង្គ | |
| ៩ | ឯកឧត្តម វ៉ាន់ ផាន់នី | - | នាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប | |
| ១០ | លោក ហុង ហ៊ី | - | នាយអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប | |

Downloaded from http://www.khmerlaws.com

**ប្រការ ២ :**

- ចំពោះមន្ត្រីនគរបាលយុត្តិធម៌ជលផលថ្នាក់កណ្តាល : មានសមត្ថកិច្ចដែនដីនៅលើវិសាលភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ។

- ចំពោះមន្ត្រីនគរបាលយុត្តិធម៌ជលផលថ្នាក់អធិការដ្ឋាន និងខណ្ឌរដ្ឋបាលជលផល : មានសមត្ថកិច្ចដែនដីនៅលើវិសាលភាពទៅលើមណ្ឌលរដ្ឋបាលដែលមន្ត្រីនោះត្រូវចាត់តាំងឱ្យទៅបំពេញការងារ លើកលែងតែការពន្យាតសមត្ថកិច្ចដែនដីដែលមានចែងក្នុងមាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ប្រការ ៣ :**

មន្ត្រីដូចបានតែងតាំងក្នុងប្រការ១ និងប្រការ២ខាងលើ នឹងទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនស្របតាមនីតិវិធីដូចមានចែងនៅក្នុងច្បាប់ស្តីពីជលផល និងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤ :**

សាមីខ្លួនដូចមានឈ្មោះក្នុងប្រការ ១ និងប្រការ ២ និងស្ថាប័នពាក់ព័ន្ធទាំងអស់មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៨

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ចាន់ សារុន

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ វង្សវឌ្ឍនា

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- សាលាឧទ្ធរណ៍
- អយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត-ក្រុង
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com

# ឧបសម្ព័ន្ធទី៦

# គំរូសុំពីសម្បថ

## ឧបសម្ព័ន្ធ
## នីតិវិធីក្នុងការធ្វើសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិ នៅទីកន្លែងនៃតុលាការនីមួយៗ ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មកក្រឡាបញ្ជីត្រូវអានប្រារព្ធវាចខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់ រួចអាន **ពាក្យសច្ចាប្រណិធាន** ឱ្យអ្នកស្បថ ថាតាម ។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថា បានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

### ប្រណិធាន

បពិត្រអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើរ ព្រះអង្គ ក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតា ក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះ ពីរវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្វែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតី ក្នុងពិធីសម្បថនេះ ស្បិតគូក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះ មកធ្វើជាសាក្សី ឱ្យឆ្លើយឱ្យបានទៀងត្រង់តាមពិត ។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោង យ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀង

ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលោភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីឫសក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រលាញ់ រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តី បំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្សអ្នកតា និងបារមីឫសក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

# ឧបសម្ព័ន្ធទី៦

# គំរូសញ្ញាបត្រ និងវិញ្ញាបនបត្រ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រ

## វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី ១៦

បញ្ជាក់ថា : លោកវរសេនីយ៍ត្រី **ម៉ុំង សុខលុច** អត្តលេខ ១០៨ ៣៦៥

តួនាទីជំនួយការការិយាល័យសន្តិសុខ អ.ហ រាជធានី

បានបញ្ចប់ : វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ជំនាន់ទី ១៦

ពីថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០១១ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

ភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

មេបញ្ជាការ

លេខ: ៣៩ /ស.ស.រ./២០១១

នាយឧត្តមសេនីយ៍ សៅ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ២៥០/២០១១ ស.ណ.ក របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ស្ដីពីមន្ត្រីកងរាជអាវុធហត្ថ ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចមានចែងក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : **លោក ម៉ាំង សុខលុច** កើតថ្ងៃទី **០៥** ខែ **កក្កដា** ឆ្នាំ **១៩៨០**

ឋានន្តរសក្តិ **វរសេនីយ៍ត្រី** អត្តលេខ **១០៨ ៣៦៥** មុខតំណែង **ជំនួយការ ការិយាល័យសន្តិសុខ**

អង្គភាព : **មន្ទីរព័ត៌មាន និងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ**

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា **៦១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ សំរាប់ទទួល

សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : **លោកវរសេនីយ៍ត្រី ម៉ាំង សុខលុច** នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១

លេខ **០៧៣៩/១១** ន.ប.យ.ន.អ.ហ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការពារជាតិ

ទាហានឧត្តមសេនីយ៍ ទៀ-បាញ់

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ-វង្សវឌ្ឍនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ

# សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ៩២១ អ.ស របស់អគ្គស្នងការដ្ឋាននគរបាលជាតិ. ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីមន្ត្រីនគរបាល ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចបានចែងក្នុងមាត្រា ៦០ និងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : ____________________ កើតថ្ងៃទី ______ ខែ ______ ឆ្នាំ ______

ឋានន្តរសក្តិ ____________________ អត្តលេខ ______ ឋានៈ ______

អង្គភាព : នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សំរាប់ទទួល សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : ____________________

នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

លេខ: ន.ប.យ.ធ

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
អង្គ.វង្សវឌ្ឍនា

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
ស ខេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាភូមិន្ទនគរបាល

# វិញ្ញាបនបត្របញ្ជាក់ការសិក្សា

**នាយកសាលាភូមិន្ទនគរបាល**

## CERTIFICAT DE SCOLARITE

**Le Directeur de l'Ecole Royale de Police**

បញ្ជាក់ថា:................................ កើតថ្ងៃទី................................ នៅ..........ភ្នំពេញ..........

**Certifie que** ................................ **né(e)le** ................................ **à** .......... Phnom Penh ..........

បានរៀនចប់វគ្គ..........បណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌.......... និទ្ទេស.......................... នៅសាលាភូមិន្ទនគរបាល

**a suivi le starge** .......... Classe de formation des Policiers Judiciers .......... **Mention** .......................... **à l'Ecole Royale de police**

ចាប់ពីថ្ងៃទី..២០....ខែ.....មិថុនា.......ឆ្នាំ២០០.៧.....ដល់ថ្ងៃទី..២២....ខែ......មិថុនា.....ឆ្នាំ២០០.៧.....។

**du** .................... 20 June 2007 .................... **au** .................... 22 June 2007 ....................

វិញ្ញាបនបត្រនេះត្រូវបានចេញឱ្យសាមីជនដើម្បីប្រើប្រាស់ តាមការដែលអាចប្រើបាន។

**Le présent certificat lui est délivré pour servir et valoir ce que de droit.**

រាជធានីភ្នំពេញ, ថ្ងៃទី..២៨.....ខែសីហា...ឆ្នាំ២០០៧.

លេខ:..........................

**Phnom Penh, le** ..........................................

**នាយកសាលាភូមិន្ទនគរបាល**

**Le directeur de l'Ecole Royale de Police**

ឧត្តមសេនីយ៍ឯក ម៉ៅ ចាន់ធឿន